ប្រសិនបើ $x=1$ នោះនាំឱ្យ $x^2<y+1$ ទៅជា $1<y+1\Leftrightarrow y>0$ ( ពិត ) ចំពោះ $\forall y\in A$

ដោយ សំណើខាងលើ ( ពិត )

នាំឱ្យគេបាន តម្លៃភាពពិតនៃសំណើខាងលើស្មើ 1 ឬ $T$

∴ សំណើ $\exists x,\forall y:\ x^2<y+1$ មានតម្លៃភាពពិតស្មើ 1 ឬ $T$

ខ. $\forall x,\exists y:\ x^2+y^2<12$

ចំពោះ $\forall x\in A$ ប្រសិនបើ $y=1$ នោះនាំឱ្យ $x^2+y^2<12$ ទៅជា $x^2+1<12$

$\Leftrightarrow x^2<11$ ( ពិត )

ដោយ សំណើខាងលើ ( ពិត )

នាំឱ្យគេបាន តម្លៃភាពពិតនៃសំណើខាងលើស្មើ 1 ឬ $T$

∴ សំណើ $\forall x,\exists y:\ x^2+y^2<12$ មានតម្លៃភាពពិតស្មើ 1 ឬ $T$

គ. $\forall x,\forall y:\ x^2+y^2<12$

ប្រសិនបើ $x=2$ និង $y=3$ នោះនាំឱ្យ $x^2+y^2<12$ ទៅជា $2^2+3^2<12$ $\Leftrightarrow 13<12$ ( មិនពិត )

ដោយ សំណើខាងលើ ( មិនពិត )

នាំឱ្យគេបាន តម្លៃភាពពិតនៃសំណើខាងលើស្មើ 0 ឬ $F$

∴ សំណើ $\forall x,\forall y:\ x^2+y^2<12$ មានតម្លៃភាពពិតស្មើ 0 ឬ $F$

ឃ. $\exists x, \forall y, \exists z : x^2 + y^2 < 2z^2$

ប្រសិនបើ $x = 1$ និង $z = 3$ នោះនាំឱ្យ $x^2 + y^2 < 2z^2$ ទៅជា $1^2 + y^2 < 2 \times 3^2$

$\Leftrightarrow 1 + y^2 < 18$ ( ពិត ) ចំពោះ $\forall y \in A$

ដោយ សំណើខាងលើ ( ពិត )

នាំឱ្យគេបាន តម្លៃភាពពិតនៃសំណើខាងលើស្មើ 1 ឬ $T$

∴ សំណើ $\exists x, \forall y, \exists z : x^2 + y^2 < 2z^2$ មានតម្លៃភាពពិតស្មើ 1 ឬ $T$

ង. $\exists x, \exists y, \forall z : x^2 + y^2 < 2z^2$

ប្រសិនបើ $z = 1$ នោះនាំឱ្យ $x^2 + y^2 < 2z^2$ ទៅជា $x^2 + y^2 < 2 \times 1^2 \Leftrightarrow x^2 + y^2 < 2$ ( មិនពិត )

ដោយ សំណើខាងលើ ( មិនពិត )

នាំឱ្យគេបាន តម្លៃភាពពិតនៃសំណើខាងលើស្មើ 0 ឬ $F$

∴ សំណើ $\exists x, \exists y, \forall z : x^2 + y^2 < 2z^2$ មានតម្លៃភាពពិតស្មើ 0 ឬ $F$

24. ដាក់ឈ្នាប់មិនលើសំណើនៃលំហាត់ ( 23 )

- តាមសំណួរ ( ក ) នៃលំហាត់លេខ ( 23 )

គេមាន $\exists x, \forall y : x^2 < y + 1$

ដោយដាក់ឈ្នាប់មិនលើសំណើ $\exists x, \forall y : x^2 < y + 1$ គេបាន :

$\neg[\ \exists x, \forall y : x^2 < y + 1\ ] \equiv \forall x, \exists y : \neg(x^2 < y + 1) \equiv \forall x, \exists y : x^2 \geq y + 1$

$\therefore$ ឈ្នាប់មិននៃសំណើ $\exists x, \forall y : x^2 < y+1$ គឺ $\forall x, \exists y : x^2 \geq y+1$

- តាមសំណួរ ( ខ ) នៃលំហាត់លេខ ( 23 )

គេមាន $\forall x, \exists y : x^2 + y^2 < 12$

ដោយដាក់ឈ្នាប់មិនលើសំណើ $\forall x, \exists y : x^2 + y^2 < 12$ គេបាន :

$$\neg[\ \forall x, \exists y : x^2 + y^2 < 12\ ] \equiv \exists x, \forall y : \neg(x^2 + y^2 < 12) \equiv \exists x, \forall y : x^2 + y^2 \geq 12$$

$\therefore$ ឈ្នាប់មិននៃសំណើ $\forall x, \exists y : x^2 + y^2 < 12$ គឺ $\exists x, \forall y : x^2 + y^2 \geq 12$

- តាមសំណួរ ( គ ) នៃលំហាត់លេខ ( 23 )

គេមាន $\forall x, \forall y : x^2 + y^2 < 12$

ដោយដាក់ឈ្នាប់មិនលើសំណើ $\forall x, \forall y : x^2 + y^2 < 12$ គេបាន :

$$\neg[\ \forall x, \forall y : x^2 + y^2 < 12\ ] \equiv \exists x, \exists y : \neg(x^2 + y^2 < 12) \equiv \exists x, \exists y : x^2 + y^2 \geq 12$$

$\therefore$ ឈ្នាប់មិននៃសំណើ $\forall x, \forall y : x^2 + y^2 < 12$ គឺ $\exists x, \exists y : x^2 + y^2 \geq 12$

- តាមសំណួរ ( ឃ ) នៃលំហាត់លេខ ( 23 )

គេមាន $\exists x, \forall y, \exists z : x^2 + y^2 < 2z^2$

ដោយដាក់ឈ្នាប់មិនលើសំណើ $\exists x, \forall y, \exists z : x^2 + y^2 < 2z^2$ គេបាន :

$$\neg[\ \exists x, \forall y, \exists z : x^2 + y^2 < 2z^2\ ] \equiv \forall x, \exists y, \forall z : \neg(x^2 + y^2 < 2z^2)$$

$$\equiv \forall x, \exists y, \forall z : x^2 + y^2 \geq 2z^2$$

∴ ឈ្នាប់មិននៃសំណើ $\exists x, \forall y, \exists z : x^2 + y^2 < 2z^2$ គឺ $\forall x, \exists y, \forall z : x^2 + y^2 \geq 2z^2$

- តាមសំណួរ ( ង ) នៃលំហាត់លេខ ( 23 )

គេមាន $\exists x, \exists y, \forall z : x^2 + y^2 < 2z^2$

ដោយដាក់ឈ្នាប់មិនលើសំណើ $\exists x, \exists y, \forall z : x^2 + y^2 < 2z^2$ គេបាន :

$$\neg[\ \exists x, \exists y, \forall z : x^2 + y^2 < 2z^2\ ] \equiv \forall x, \forall y, \exists z : \neg\left(x^2 + y^2 < 2z^2\right)$$

$$\equiv \forall x, \forall y, \exists z : x^2 + y^2 \geq 2z^2$$

∴ ឈ្នាប់មិននៃសំណើ $\exists x, \exists y, \forall z : x^2 + y^2 < 2z^2$ គឺ $\forall x, \forall y, \exists z : x^2 + y^2 \geq 2z^2$

25. ដាក់ឈ្នាប់មិនលើសំណើខាងក្រោម :

ក. $\forall x, \exists y : [P(x) \vee Q(y)]$

ដោយដាក់ឈ្នាប់មិនលើសំណើ $\forall x, \exists y : [P(x) \vee Q(y)]$ គេបាន :

$$\neg\{\ \forall x, \exists y : [P(x) \vee Q(y)]\ \} \equiv \exists x, \forall y : \neg[P(x) \vee Q(y)]$$

$$\equiv \exists x, \forall y : [\neg P(x) \wedge \neg Q(y)]$$

∴ ឈ្នាប់មិននៃសំណើ $\forall x, \exists y : [P(x) \vee Q(y)]$ គឺ $\exists x, \forall y : [\neg P(x) \wedge \neg Q(y)]$

ខ. $\exists x, \forall y : [P(x, y) \rightarrow Q(x, y)]$

ដោយដាក់ឈ្នាប់មិនលើសំណើ $\exists x, \forall y : [P(x, y) \rightarrow Q(x, y)]$ គេបាន :

$$\neg\{\ \exists x,\forall y : [P(x,y)\to Q(x,y)]\ \} \equiv \forall x,\exists y : \neg[P(x,y)\to Q(x,y)]$$

$$\equiv \forall x,\exists y : \neg[\neg P(x,y)\vee Q(x,y)]$$

$$\equiv \forall x,\exists y : [P(x,y)\wedge\neg Q(x,y)]$$

$\therefore$ ឈ្នាប់មិននៃសំណើ $\exists x,\forall y : [P(x,y)\to Q(x,y)]$ គឺ $\forall x,\exists y : [P(x,y)\wedge\neg Q(x,y)]$

ននននន 📖 ឧឧឧឧ

## លំហាត់ផ្នែកទ្រឹស្តីសំណុំ

1. រកសំណុំដែលស្មើគ្នាក្នុងចំណោមសំណុំខាងក្រោម :

$A=\{x : x^2-4x+3=0\}$

$B=\{x : x^2-3x+2=0\}$

$C=\{x : x\in\mathbb{N}^* ,\ x<3\}$

$D=\{x : x\in\mathbb{N} : x \text{ is odd} ,\ x<5\}$

2. គេឱ្យ $A=\{1,2,3,4,5,6,7,8,9\}$ , $B=\{2,4,6,8\}$ , $C=\{1,3,5,7,9\}$ , $D=\{3,4,5\}$ , $E=\{3,5\}$

តើសំណុំ $X$ ស្មើនឹងសំណុំណាមួយក្នុងចំណោមសំណុំខាងលើ ដោយគេដឹងថា :

i. $X$ និង $B$ ជាសំណុំដាច់គ្នា

ii. $X\subset D$ តែ $X\not\subset B$

iii. $X\subset A$ តែ $X\not\subset C$

iv. $X\subset C$ តែ $X\not\subset A$

3. នៅក្នុងប្លង់មួយគេតាង :

- $Q$ ជាសំណុំនៃចតុកោណ
- $T$ ជាសំណុំចតុកោណព្នាយ
- $C$ ជាសំណុំការេ
- $P$ ជាសំណុំប្រលេឡូក្រាម
- $R$ ជាសំណុំចតុកោណកែង
- $L$ ជាសំណុំចតុកោណស្មើ

ក. ចូររកទំនាក់ទំនងតាម " ភាពនៅក្នុង " រវាងសំណុំខាងលើ ។

ខ. ចូររកសំណុំ $L \cap R$ , $Q \cap P$ , $C \cup R$ , $L - Q$ , $L \cap R \cap T$

គ. គូស Venn diagram តាងឱ្យទំនាក់ទំនងនៃសំណុំខាងលើ ។

4. នៅក្នុងប្លង់មួយគេតាង :

- $T$ ជាសំណុំត្រីកោណ
- $E$ ជាសំណុំត្រីកោណសម័ង្ស
- $I$ ជាសំណុំត្រីកោណសមបាត
- $R$ ជាសំណុំត្រីកោណកែង
- $B$ ជាសំណុំត្រីកោណដែលមានមុំទាល

ក. ចូររកទំនាក់ទំនងតាម " ភាពនៅក្នុង " រវាងសំណុំខាងលើ ។

ខ. ចូររកសំណុំ $E \cap R$ , $E \cap B$ , $R \cap B$ , $T \cap I$ , $T \cup I$ , $I - T$ , $I \cap B$ , $T - I$

គ. គូស Venn diagram តាងឱ្យទំនាក់ទំនងនៃសំណុំខាងលើ ។

5. ក្នុងសកល $\mathbb{R}$ គេឱ្យសំណុំ $E$ , $F$ , $G$ , $H$ កំណត់ដូចខាងក្រោម :

$E = \{x : x \in \mathbb{R} , \ x + 5 > 0\}$ $\qquad$ $G = \{x : x \in \mathbb{R} , \ x + 5 < 0\}$

$F = \{x : x \in \mathbb{R} , \ x - 2 > 0\}$ $\qquad$ $H = \{x : x \in \mathbb{R} , \ x - 2 < 0\}$

ចូរសរសេរសំណុំ $A = \{x : x \in \mathbb{R} , \ (x+5)(x-2) > 0\}$ ជាអនុគមន៍នៃ $E$ , $F$ , $G$ , $H$ ។

6. គេឱ្យសំណុំ $M=\left\{ \ x : x=\dfrac{n+7}{n+1} \ , n\in\mathbb{N}^{*} \ \right\}$

កំណត់សំណុំរង $A$ នៃ $M$ ដែល $A=\left\{ \ x\in M : x\in\mathbb{Z} \ \right\}$ ។

7. គេឱ្យ $A$ , $B$ ជាសំណុំ ។ បង្ហាញថា :

i. $A\cup B=B\cup(A-B)$

ii. $B\cap(A-B)=\varnothing$

iii. $A=(A-B)\cup(A\cap B)$

iv. $(A-B)\cap(A\cap B)=\varnothing$

v. $A-B=A\cap\overline{B}$

vi. $(A-B)-C=A-(B\cup C)$

vii. $(A-B)\cap(A-C)=A-(B\cup C)$

viii. $(A-B)\cup(A-C)=A-(B\cap C)$

8. គេឱ្យ $A$ , $B$ ជាសំណុំ ។ បង្ហាញថា :

i. $A\cup(A\cap B)=A$

ii. $A\cap(A\cup B)=A$

9. គេឱ្យបីសំណុំ $A$ , $B$ , $C$ ។

i. បង្ហាញថា : $A\cap(B-C)=(A\cap B)-(A\cap C)$

ii. រកឧទាហរណ៍ដើម្បីបញ្ជាក់ថា : $A\cup(B-C)\neq(A\cup B)-(A\cup C)$

10. គេឱ្យបីសំណុំ $A$ , $B$ , $C$ ។ ចូរសម្រួល :

i. $[A\cup(A\cap B)]\cap B$

ii. $(A\cup B)\cap(B\cap C)\cap(C\cup A)$

iii. $(A\cap B)\cup(A\cap\overline{B})$

iv. $(\overline{A\cup B})\cap(C\cup\overline{A})$

v. $(A\cap B)\cup(A\cap\overline{B})\cup(\overline{A}\cap B)$

vi. $A\cap B\cap(B\cup\overline{C})$

vii. $\overline{[(\overline{A\cap B})\cap(\overline{A\cap C})]\cup A}$

viii. $A\cup\{[B\cap(A\cup B)]\cap[A\cup(A\cap B)]\}$

ix. $A\cap(\overline{A}\cup B)$

11. គេឱ្យបួនសំណុំ $A$ , $B$ , $C$ , $D$ ។

i. បង្ហាញថា បើ $A\subset B$ និង $C\subset D$ នោះគេបាន $A\cap C\subset B\cap D$ និង $A\cup C\subset B\cup D$

ii. បង្ហាញថា បើ $A\subset B$ នោះគេបាន $A\cap C\subset B\cap C$ និង $A\cup C\subset B\cup C$

iii. បើ $A\cap C\subset B\cap C$ តើគេបាន $A\subset B$ ឬទេ ?

iv. បើ $A\cup C\subset B\cup C$ តើគេបាន $A\subset B$ ឬទេ ?

v. បើ $A\cap C\subset B\cap C$ និង $A\cup C\subset B\cup C$ តើគេបាន $A\subset B$ ឬទេ ?

12. រក Dual នៃសមភាពខាងក្រោម :

i. $A\cup(A\cap B)=A$

ii. $(A\cap B)\cup(\overline{A}\cap B)\cup(A\cap\overline{B})\cup(\overline{A}\cap\overline{B})=U$

iii. $(U\cap A)\cup(B\cap A)=A$

iv. $(A\cap U)\cap(\varnothing\cup\overline{A})=\varnothing$

v. $(A\cup U)\cap(A\cap\varnothing)=\varnothing$

vi. $\overline{A\cup B\cup C}=\overline{A\cup C}\cap\overline{A\cup B}$

vii. $\overline{A\cap U}\cap A=\varnothing$

viii. $A\cup B=\overline{\overline{A}\cap\overline{B}}$

ix. $(A\cap U)\cap(B\cup C)=(A\cap B)\cup(A\cap C)$

x. $\overline{A}\cup\overline{B}\cup\overline{C}=\overline{A\cap B\cap C}$

13. គេឱ្យបីសំណុំ $A , B , C$ ។

i. បើ $A\cap C = B\cap C$ តើគេបាន $A = B$ ឬទេ ?

ii. បើ $A\cup C = B\cup C$ តើគេបាន $A = B$ ឬទេ ?

iii. បើ $A\cap C = B\cap C$ និង $A\cup C = B\cup C$ តើគេបាន $A = B$ ឬទេ ?

14. ការស្ទង់មតិចំពោះនិស្សិតចំនួន 100 នាក់ឱ្យលទ្ធផលតាមស្ថិតិដូចខាងក្រោម :

32 នាក់រៀនគណិតវិទ្យា , 20 នាក់រៀនរូបវិទ្យា , 45 នាក់រៀនជីវវិទ្យា , 15 នាក់រៀនគណិតវិទ្យា និង ជីវវិទ្យា

7 នាក់រៀនគណិតវិទ្យា និង រូបវិទ្យា , 10 នាក់រៀនរូបវិទ្យា និង ជីវវិទ្យា , 30 នាក់មិនរៀនទាំងបីមុខវិជ្ជា ។




ក. រកចំនួននិស្សិតដែលរៀនទាំងបីមុខវិជ្ជា ។

ខ. រកចំនួននិស្សិតដែលរៀនតែពីរមុខវិជ្ជា ។

គ. រកចំនួននិស្សិតដែលរៀនតែមួយមុខវិជ្ជា ។

បញ្ជាក់ : បំពេញចំនួនខាងលើក្នុង Venn diagram ខាងលើ ។

15. ការស្ទង់មតិចំពោះប្រជាជន 60 នាក់ឱ្យលទ្ធផលតាមស្ថិតិដូចខាងក្រោម :

25 នាក់អានទស្សនាវដ្ដីប្រជាប្រិយ , 26 នាក់អានទស្សនាវដ្ដីកុលធីតា , 26 នាក់អានទស្សនាវដ្ដីអង្គរធំ

9 នាក់អានទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីកុលធីតា , 11 នាក់អានទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីអង្គរធំ

8 នាក់អានទស្សនាវដ្ដីកុលធីតា និង ទស្សនាវដ្ដីអង្គរធំ , 8 នាក់មិនអានទាំងបីទស្សនាវដ្ដី ។




ក. រកចំនួនប្រជាជនដែលអានតទាំងបីទស្សនាវដ្ដី ។

ខ. រកចំនួនប្រជាជនដែលអានតែពីរទស្សនាវដ្ដី ។

គ. រកចំនួនប្រជាជនដែលអានតែមួយទស្សនាវដ្ដី ។

បញ្ជាក់ : បំពេញចំនួនខាងលើក្នុង Venn diagram ខាងលើ ។

16. គេឱ្យសំណុំ $A = \{1,2,3,4,5\}$ ។ រកថ្នាក់ $\mathcal{A}$ ដែល :

ក. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមិនមានធាតុ 2 និង 4 ។

ខ. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានផលបូកធាតុទាំងអស់ស្មើនឹង 5 ។

គ. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានបួនធាតុ ។

17. រក Power set $\wp(A)$ ដែល :

ក. $A=\{a,b,c\}$

ខ. $A=\{1,2,3,4\}$

គ. $A=\{a,b,c,d,e\}$

18. សិក្សាសុពលភាព ( validity ) នៃ Argument ខាងក្រោម :

$S_1$ : និស្សិតទាំងអស់សុទ្ធតែជាមនុស្សឧស្សាហ៍

$S_2$ : គ្មានអ្នកក្រណាម្នាក់ជានិស្សិត

---

$S$ : មនុស្សឧស្សាហ៍សុទ្ធតែមិនមែនជាអ្នកក្រ

19. បង្ហាញថា :

i. $1^2+2^2+3^2+\cdots\cdots+n^2=\dfrac{n(n+1)(2n+1)}{6}$

ii. $1+4+7+\cdots\cdots+(3n-2)=\dfrac{n(3n-1)}{2}$

iii. $\dfrac{1}{1.3}+\dfrac{1}{3.5}+\cdots\cdots+\dfrac{1}{(2n-1)(2n+1)}=\dfrac{n}{2n+1}$

iv. $n!\geq 2^n$ , for $\forall n\geq 4$

20. គេឱ្យពីរសំណុំ $A$ , $B$ ។

គេបានផលសងឆ្លុះនៃ $A$ និង $B$ កំណត់សរសេរដោយ : $A\Delta B=(A\cup B)\setminus(A\cap B)$ ។

a) Given $A=\{1,2,3,4,5,6\}$ , $B=\{4,5,6,7,8,9\}$ , $C=\{1,3,5,7,9\}$ , $D=\{2,3,5,7,8\}$

រក $A\Delta B$ , $B\Delta C$ , $C\Delta D$ , $A\Delta D$ , $A\cap(B\Delta D)$ , $(A\cap B)\Delta(A\cap D)$

b) បង្ហាញថា : $A\Delta B=(A-B)\cup(B-A)$

# ផ្នែកដំណោះស្រាយ

## ផ្នែកទ្រឹស្តីសំណុំ

1. រកសំណុំដែលស្មើគ្នាក្នុងចំណោមសំណុំខាងក្រោម :

$A=\{x:x^2-4x+3=0\}$ $\quad C=\{x:x\in\mathbb{N}^*\ ,\ x<3\}$

$B=\{x:x^2-3x+2=0\}$ $\quad D=\{x:x\in\mathbb{N}:\ x\ \text{ is odd}\ ,\ x<5\}$

- $A=\{x:x^2-4x+3=0\}$

ដោយសមីការ $x^2-4x+3=0$ មានឫស $\left[\begin{array}{l}x=1\\x=3\end{array}\right.$

នាំឱ្យសំណុំ $A=\{1,3\}$

- $B=\{x:x^2-3x+2=0\}$

ដោយសមីការ $x^2-3x+2=0$ មានឫស $\left[\begin{array}{l}x=1\\x=2\end{array}\right.$

នាំឱ្យសំណុំ $B=\{1,2\}$

- $C=\{x:x\in\mathbb{N}^*\ ,\ x<3\}$

ដោយ $x\in\mathbb{N}^*$ , $x<3$ គេបាន $x=1\ ,\ 2$

នាំឱ្យសំណុំ $C=\{1,2\}$

- $D=\{x:x\in\mathbb{N}:\ x\ \text{ is odd}\ ,\ x<5\}$

ដោយ $x\in\mathbb{N}$ : $x$ is odd , $x<5$ គេបាន $x=1\ ,\ 3$

នាំឱ្យសំណុំ $D=\{1,3\}$

$\therefore$ $A = D = \{1,3\}$ & $B = C = \{1,2\}$

2. គេឱ្យ $A = \{1,2,3,4,5,6,7,8,9\}$ , $B = \{2,4,6,8\}$ , $C = \{1,3,5,7,9\}$ , $D = \{3,4,5\}$ , $E = \{3,5\}$

តើសំណុំ $X$ ស្មើនឹងសំណុំណាមួយក្នុងចំណោមសំណុំខាងលើ ដោយគេដឹងថា :

i. $X$ និង $B$ ជាសំណុំដាច់គ្នា

ដើម្បីឱ្យ $X$ និង $B$ ជាសំណុំដាច់គ្នា លុះត្រាតែ $X \cap B = \varnothing$

$\therefore$ $X = C = \{1,3,5,7,9\}$ , $X = E = \{3,5\}$

ii. $X \subset D$ តែ $X \not\subset B$

$X \subset D \Leftrightarrow \forall x \in X \Rightarrow x \in D$

$X \not\subset B \Leftrightarrow \exists x \in X$ ដែល $x \notin B$

$\therefore$ $X = E = \{3,5\}$

iii. $X \subset A$ តែ $X \not\subset C$

$X \subset A \Leftrightarrow \forall x \in X \Rightarrow x \in A$

$X \not\subset C \Leftrightarrow \exists x \in X$ ដែល $x \notin C$

$\therefore$ $X = B = \{2,4,6,8\}$ , $X = D = \{3,4,5\}$

iv. $X \subset C$ តែ $X \not\subset A$

$X \subset C \Leftrightarrow \forall x \in X \Rightarrow x \in C$

$X \not\subset A \Leftrightarrow \exists x \in X$ ដែល $x \notin A$

តាមការសង្កេតមើលសំណុំខាងលើ យើងឃើញថា $A \subset A$ , $B \subset A$ , $C \subset A$ , $D \subset A$ , $E \subset A$

$\therefore$ | គេមិនអាចរកសំណុំ $X$ ដែលផ្ទៀងផ្ទាត់លក្ខ័ណ្ឌខាងលើនេះបានទេ |

3. នៅក្នុងប្លង់មួយគេតាង :

- $Q$ ជាសំណុំនៃចតុកោណ
- $T$ ជាសំណុំចតុកោណព្នាយ
- $C$ ជាសំណុំការេ
- $P$ ជាសំណុំប្រលេឡូក្រាម
- $R$ ជាសំណុំចតុកោណកែង
- $L$ ជាសំណុំចតុកោណស្មើ

ក. ចូររកទំនាក់ទំនងតាម “ ភាពនៅក្នុង ” រវាងសំណុំខាងលើ ។

$\therefore$ | $C \subset L \subset R \subset P \subset T \subset Q$ |

ខ. ចូររកសំណុំ $L \cap R$ , $Q \cap P$ , $C \cup R$ , $L - Q$ , $L \cap R \cap T$

$\therefore$

$L \cap R = C$

$Q \cap P = P$ ( ព្រោះ: $P \subset Q$ )

$C \cup R = R$ ( ព្រោះ: $C \subset R$ )

$L - Q = \varnothing$ ( ព្រោះ: $L \subset Q$ )

$L \cap R \cap T = (L \cap R) \cap T = C \cap T = C$ ( ព្រោះ: $L \cap R = C$ & $C \subset T$ )

គ. គូស Venn diagram តាងឱ្យទំនាក់ទំនងនៃសំណុំខាងលើ ។

$$C \subset L \subset R \subset P \subset T \subset Q$$




4. នៅក្នុងប្លង់មួយគេតាង :

- $T$ ជាសំណុំត្រីកោណ
- $E$ ជាសំណុំត្រីកោណសម័ង្ស
- $I$ ជាសំណុំត្រីកោណសមបាត
- $R$ ជាសំណុំត្រីកោណកែង
- $B$ ជាសំណុំត្រីកោណដែលមានមុំទាល

ក. ចូររកទំនាក់ទំនងតាម “ ភាពនៅក្នុង ” រវាងសំណុំខាងលើ ។

$$\therefore \boxed{E \subset I \subset T \ , \ R \subset T \ , \ B \subset T}$$

ខ. ចូររកសំណុំ $E\cap R$ , $E\cap B$ , $R\cap B$ , $T\cap I$ , $T\cup I$ , $I-T$ , $I\cap B$ , $T-I$

$\therefore$

$E\cap R=\varnothing$ ( ព្រោះគ្មានត្រីកោណសម័ង្សណាដែលមានមុំកែងទេ )

$E\cap B=\varnothing$ ( ព្រោះគ្មានត្រីកោណសម័ង្សណាដែលមានមុំទាលទេ )

$R\cap B=\varnothing$ ( ព្រោះគ្មានត្រីកោណកែងណាដែលមានមុំទាលទេ )

$T\cap I=I$ ( ព្រោះ $I\subset T$ )

$T\cup I=T$ ( ព្រោះ $I\subset T$ )

$I-T=\varnothing$ ( ព្រោះ $I\subset T$ )

$I\cap B=$ សំណុំនៃត្រីកោណសមបាតដែលមានមុំទាល

$T-I=$ សំណុំនៃត្រីកោណដែលមិនសមបាត

គ. គូស Venn diagram តាងឱ្យទំនាក់ទំនងនៃសំណុំខាងលើ ។




$B\subset T$




$E\subset I\subset T$




$R\subset T$

5. ក្នុងសកល $\mathbb{R}$ គេឱ្យសំណុំ $E$ , $F$ , $G$ , $H$ កំណត់ដូចខាងក្រោម :

$E=\{x : x\in\mathbb{R} , x+5>0\}$ $G=\{x : x\in\mathbb{R} , x+5<0\}$

$F=\{x : x\in\mathbb{R} , x-2>0\}$ $H=\{x : x\in\mathbb{R} , x-2<0\}$

ចូរសរសេរសំណុំ $A=\{x : x\in\mathbb{R} , (x+5)(x-2)>0\}$ ជាអនុគមន៍នៃ $E$ , $F$ , $G$ , $H$ ។

- $(x+5)(x-2)>0 \Leftrightarrow \begin{cases} x+5>0 \\ x-2>0 \end{cases}$ ឬ $\begin{cases} x+5<0 \\ x-2<0 \end{cases}$

នាំឱ្យសំណុំ $A=(E\cap F)\cup(G\cap H)$

$\therefore$ $\boxed{A=(E\cap F)\cup(G\cap H)}$

6. គេឱ្យសំណុំ $M=\left\{ x : x=\dfrac{n+7}{n+1} , n\in\mathbb{N}^* \right\}$

កំណត់សំណុំរង $A$ នៃ $M$ ដែល $A=\{ x\in M : x\in\mathbb{Z} \}$ ។

$$\frac{n+7}{n+1}=\frac{(n+1)+6}{n+1}=1+\frac{6}{n+1}$$

ដោយ $n\in\mathbb{N}^*$ ដើម្បីឱ្យ 6 ចែកដាច់នឹង $n+1$ លុះត្រាតែ $n=1 , 2 , 5$

+ ចំពោះ $n=1 \Rightarrow x=1+\dfrac{6}{n+1}=1+\dfrac{6}{1+1}=1+3=4$

+ ចំពោះ $n=2 \Rightarrow x=1+\dfrac{6}{n+1}=1+\dfrac{6}{2+1}=1+2=3$

+ ចំពោះ $n=5 \Rightarrow x=1+\dfrac{6}{n+1}=1+\dfrac{6}{5+1}=1+1=2$

$\therefore$ សំណុំរង $A$ នៃ $M$ គឺ $A=\varnothing , \{2\} , \{3\} , \{4\} , \{2,3\} , \{2,4\} , \{3,4\} , \{2,3,4\}$

7. គេឱ្យ $A$ , $B$ ជាសំណុំ ។ បង្ហាញថា :

i. $A\cup B=B\cup(A-B)$

- $B\cup(A-B)=B\cup(A\cap\overline{B})=(B\cup A)\cap(B\cup\overline{B})=(B\cup A)\cap U=B\cup A=A\cup B$

( ដែល $U$ ជាសំណុំសកល )

$\therefore$ $\boxed{A\cup B=B\cup(A-B)}$

ii. $B\cap(A-B)=\varnothing$

- $B\cap(A-B)=B\cap(A\cap\overline{B})=B\cap(\overline{B}\cap A)=(B\cap\overline{B})\cap A=\varnothing\cap A=\varnothing$

$\therefore$ $\boxed{B\cap(A-B)=\varnothing}$

iii. $A=(A-B)\cup(A\cap B)$

- $(A-B)\cup(A\cap B)=(A\cap\overline{B})\cup(A\cap B)=[A\cup(A\cap B)]\cap[\overline{B}\cup(A\cap B)]$

$=A\cap[(\overline{B}\cup A)\cap(\overline{B}\cup B)]=A\cap[(\overline{B}\cup A)\cap U]$

$=A\cap(\overline{B}\cup A)=A\cap(A\cup\overline{B})=A$

$\therefore$ $\boxed{A=(A-B)\cup(A\cap B)}$

iv. $(A-B)\cap(A\cap B)=\varnothing$

- $(A-B)\cap(A\cap B)=(A\cap\overline{B})\cap(A\cap B)=(A\cap\overline{B})\cap(B\cap A)$

$=[A\cap(\overline{B}\cap B)]\cap A=(A\cap\varnothing)\cap A=\varnothing\cap A=\varnothing$

$\therefore$ $$(A-B)\cap(A\cap B)=\varnothing$$

v. $A-B=A\cap\overline{B}$

- $A-B=\{x : x\in A \wedge x\notin B\}=\{x : x\in A \wedge x\in\overline{B}\}=\{x : x\in(A\cap\overline{B})\}$

$\therefore$ $$A-B=A\cap\overline{B}$$

vi. $(A-B)-C=A-(B\cup C)$

- $(A-B)-C=(A\cap\overline{B})-C=(A\cap\overline{B})\cap\overline{C}$
- $A-(B\cup C)=A\cap(\overline{B\cup C})=A\cap(\overline{B}\cap\overline{C})=(A\cap\overline{B})\cap\overline{C}$

$\therefore$ $$(A-B)-C=A-(B\cup C)$$

vii. $(A-B)\cap(A-C)=A-(B\cup C)$

- $(A-B)\cap(A-C)=(A\cap\overline{B})\cap(A\cap\overline{C})=(\overline{B}\cap A)\cap(A\cap\overline{C})$

  $=[\overline{B}\cap(A\cap A)]\cap\overline{C}=(\overline{B}\cap A)\cap\overline{C}$
- $A-(B\cup C)=A\cap(\overline{B\cup C})=A\cap(\overline{B}\cap\overline{C})=(A\cap\overline{B})\cap\overline{C}=(\overline{B}\cap A)\cap\overline{C}$

$\therefore$ $$(A-B)\cap(A-C)=A-(B\cup C)$$

viii. $(A-B)\cup(A-C)=A-(B\cap C)$

- $(A-B)\cup(A-C)=(A\cap\overline{B})\cup(A\cap\overline{C})=[A\cup(A\cap\overline{C})]\cap[\overline{B}\cup(A\cap\overline{C})]$

$$=A\cap[(\overline{B}\cup A)\cap(\overline{B}\cup\overline{C})]=[A\cap(\overline{B}\cup A)]\cap(\overline{B}\cup\overline{C})$$

$$=[A\cap(A\cup\overline{B})]\cap(\overline{B}\cup\overline{C})=A\cap(\overline{B}\cup\overline{C})$$

- $A-(B\cap C)=A\cap(\overline{B\cap C})=A\cap(\overline{B}\cup\overline{C})$

$\therefore$ $\boxed{(A-B)\cup(A-C)=A-(B\cap C)}$

8. គេឱ្យ $A$ , $B$ ជាសំណុំ ។ បង្ហាញថា :

i. $A\cup(A\cap B)=A$

- $A=A\cap U=A\cap(U\cup B)=(A\cap U)\cup(A\cap B)=A\cup(A\cap B)$

( ដែល $U$ ជាសំណុំសកល )

$\therefore$ $\boxed{A\cup(A\cap B)=A}$

ii. $A\cap(A\cup B)=A$

- $A=A\cup\varnothing=A\cup(\varnothing\cap B)=(A\cup\varnothing)\cap(A\cup B)=A\cap(A\cup B)$

( ដែល $U$ ជាសំណុំសកល )

$\therefore$ $\boxed{A\cap(A\cup B)=A}$

9. គេឱ្យបីសំណុំ $A$ , $B$ , $C$ ។

i. បង្ហាញថា : $A\cap(B-C)=(A\cap B)-(A\cap C)$

- $A\cap(B-C)=A\cap(B\cap\overline{C})$
- $(A\cap B)-(A\cap C)=(A\cap B)\cap(\overline{A\cap C})=(A\cap B)\cap(\overline{A}\cup\overline{C})$

$$=\left[A\cap(\overline{A}\cup\overline{C})\right]\cap\left[B\cap(\overline{A}\cup\overline{C})\right]$$

$$=\left[(A\cap\overline{A})\cup(A\cap\overline{C})\right]\cap\left[(B\cap\overline{A})\cup(B\cap\overline{C})\right]$$

$$=\left[\varnothing\cup(A\cap\overline{C})\right]\cap\left[(B\cap\overline{A})\cup(B\cap\overline{C})\right]$$

$$=(A\cap\overline{C})\cap\left[(B\cap\overline{A})\cup(B\cap\overline{C})\right]$$

$$=\left[(A\cap\overline{C})\cap(B\cap\overline{A})\right]\cup\left[(A\cap\overline{C})\cap(B\cap\overline{C})\right]$$

$$=\left[(\overline{C}\cap A)\cap(\overline{A}\cap B)\right]\cup\left[(A\cap\overline{C})\cap(\overline{C}\cap B)\right]$$

$$=\left\{\left[\overline{C}\cap(A\cap\overline{A})\right]\cap B\right\}\cup\left\{\left[A\cap(\overline{C}\cap\overline{C})\right]\cap B\right\}$$

$$=\left[(\overline{C}\cap\varnothing)\cap B\right]\cup\left[(A\cap\overline{C})\cap B\right]=(\varnothing\cap B)\cup\left[(A\cap\overline{C})\cap B\right]$$

$$=\varnothing\cup\left[(A\cap\overline{C})\cap B\right]=(A\cap\overline{C})\cap B=A\cap(\overline{C}\cap B)=A\cap(B\cap\overline{C})$$

$\therefore$ $\boxed{A\cap(B-C)=(A\cap B)-(A\cap C)}$

ii. រកឧទាហរណ៍ដើម្បីបញ្ជាក់ថា : $A\cup(B-C)\neq(A\cup B)-(A\cup C)$

- ឧទាហរណ៍ : គេមានបីសំណុំ $A=\{a,b,c,d,e\}$ , $B=\{c,d,e,f,g\}$ និង $C=\{b,e,h\}$

គេបាន $B-C=\{c,d,f,g\}$ , $A\cup B=\{a,b,c,d,e,f,g\}$ , $A\cup C=\{a,b,c,d,e,h\}$

នាំឱ្យ $A\cup(B-C)=\{a,b,c,d,e,f,g\}$ , $(A\cup B)-(A\cup C)=\{f,g\}$

នាំឱ្យ $A\cup(B-C)\neq(A\cup B)-(A\cup C)$

$\therefore$ $\boxed{A\cup(B-C)\neq(A\cup B)-(A\cup C)}$

10. គេឱ្យបីសំណុំ $A$ , $B$ , $C$ ។ ចូរសម្រួល :

i. $[A\cup(A\cap B)]\cap B$

- $[A\cup(A\cap B)]\cap B=A\cap B$ ( ព្រោះ $A\cup(A\cap B)=A$ )

$\therefore$ $\boxed{[A\cup(A\cap B)]\cap B=A\cap B}$

ii. $(A\cup B)\cap(B\cap C)\cap(C\cup A)$

- $(A\cup B)\cap(B\cap C)\cap(C\cup A)=[(A\cup B)\cap(B\cap C)]\cap(C\cup A)$
- $(A\cup B)\cap(B\cap C)=B\cap C$ ( ព្រោះ $B\cap C\subset B\subset A\cup B$ )
- $(B\cap C)\cap(C\cup A)=B\cap C$ ( ព្រោះ $B\cap C\subset C\subset C\cup A$ )

នាំឱ្យ $[(A\cup B)\cap(B\cap C)]\cap(C\cup A)=(B\cap C)\cap(C\cup A)=B\cap C$

$\therefore$ $\boxed{(A\cup B)\cap(B\cap C)\cap(C\cup A)=B\cap C}$

iii. $(A\cap B)\cup(A\cap\overline{B})$

- $(A\cap B)\cup(A\cap\overline{B})=[A\cup(A\cap\overline{B})]\cap[B\cup(A\cap\overline{B})]=A\cap[(B\cup A)\cap(B\cup\overline{B})]$

$=A\cap[(B\cup A)\cap U]=A\cap(B\cup A)=A$

$\therefore$ $\boxed{(A\cap B)\cup(A\cap\overline{B})=A}$

iv. $(\overline{A\cup B})\cap(C\cup\overline{A})$

- $(\overline{A\cup B})\cap(C\cup\overline{A})=(\overline{A}\cap\overline{B})\cap(C\cup\overline{A})=(\overline{B}\cap\overline{A})\cap(C\cup\overline{A})$

$=\overline{B}\cap[\overline{A}\cap(C\cup\overline{A})]=\overline{B}\cap[\overline{A}\cap(\overline{A}\cup C)]=\overline{B}\cap\overline{A}$

$\therefore$ $$\left(\overline{A\cup B}\right)\cap\left(C\cup\overline{A}\right)=\overline{B}\cap\overline{A}$$

v. $\left(A\cap B\right)\cup\left(A\cap\overline{B}\right)\cup\left(\overline{A}\cap B\right)$

- $\left(A\cap B\right)\cup\left(A\cap\overline{B}\right)\cup\left(\overline{A}\cap B\right)=\left[\left(A\cap B\right)\cup\left(A\cap\overline{B}\right)\right]\cup\left(\overline{A}\cap B\right)$

( ដោយ $\left(A\cap B\right)\cup\left(A\cap\overline{B}\right)=A$ )

$$=A\cup\left(\overline{A}\cap B\right)=\left(A\cup\overline{A}\right)\cap\left(A\cup B\right)$$

$$=U\cap\left(A\cup B\right)=A\cup B$$

$\therefore$ $$\left(A\cap B\right)\cup\left(A\cap\overline{B}\right)\cup\left(\overline{A}\cap B\right)=A\cup B$$

vi. $A\cap B\cap\left(B\cup\overline{C}\right)$

- $A\cap B\cap\left(B\cup\overline{C}\right)=A\cap\left[B\cap\left(B\cup\overline{C}\right)\right]=A\cap B$

$\therefore$ $$A\cap B\cap\left(B\cup\overline{C}\right)=A\cap B$$

vii. $\overline{\left[\left(\overline{A\cap B}\right)\cap\left(\overline{A\cap C}\right)\right]\cup A}$

- $\overline{\left[\left(\overline{A\cap B}\right)\cap\left(\overline{A\cap C}\right)\right]\cup A}=\overline{\left[\left(\overline{A\cap B}\right)\cap\left(\overline{A\cap C}\right)\right]}\cap\overline{A}=\left[\left(A\cap B\right)\cup\left(A\cap C\right)\right]\cap\overline{A}$

$$=\left[A\cap\left(B\cup C\right)\right]\cap\overline{A}=\overline{A}\cap\left[A\cap\left(B\cup C\right)\right]$$

$$=\left(\overline{A}\cap A\right)\cap\left(B\cup C\right)=\varnothing\cap\left(B\cup C\right)=\varnothing$$

$\therefore$ $$\overline{\left[\left(\overline{A\cap B}\right)\cap\left(\overline{A\cap C}\right)\right]\cup A}=\varnothing$$

viii. $A\cup\{[B\cap(A\cup B)]\cap[A\cup(A\cap B)]\}$

- $A\cup\{[B\cap(A\cup B)]\cap[A\cup(A\cap B)]\}=A\cup(B\cap A)=A$

( ព្រោះ $B\cap(A\cup B)=B$ & $A\cup(A\cap B)=A$ )

$\therefore$ $\boxed{A\cup\{[B\cap(A\cup B)]\cap[A\cup(A\cap B)]\}=A}$

ix. $A\cap(\overline{A}\cup B)$

- $A\cap(\overline{A}\cup B)=(A\cap\overline{A})\cup(A\cap B)=\varnothing\cup(A\cap B)=A\cap B$

$\therefore$ $\boxed{A\cap(\overline{A}\cup B)=A\cap B}$

11. គេឱ្យបួនសំណុំ $A$ , $B$ , $C$ , $D$ ។

i. បង្ហាញថា បើ $A\subset B$ និង $C\subset D$ នោះគេបាន $A\cap C\subset B\cap D$ និង $A\cup C\subset B\cup D$

- $\forall x\in A\cap C \Leftrightarrow x\in A\wedge x\in C$

គេមាន $A\subset B$ និង $C\subset D$

$\Rightarrow x\in B\wedge x\in D$

$\Rightarrow x\in B\cap D$

គេបាន $A\cap C\subset B\cap D$

$\therefore$ $\boxed{\text{បើ } A\subset B \text{ និង } C\subset D \text{ នោះគេបាន } A\cap C\subset B\cap D}$

- $\forall x\in A\cup C \Leftrightarrow x\in A\vee x\in C$

គេមាន $A\subset B$ និង $C\subset D$

$\Rightarrow x\in B\vee x\in D$

$\Rightarrow x\in B\cup D$

គេបាន $A\cup C\subset B\cup D$

$\therefore$ | បើ $A\subset B$ និង $C\subset D$ នោះគេបាន $A\cup C\subset B\cup D$ |

ii. បង្ហាញថា បើ $A\subset B$ នោះគេបាន $A\cap C\subset B\cap C$ និង $A\cup C\subset B\cup C$

- តាមសំណួរ ( i ) គេមាន បើ $A\subset B$ និង $C\subset D$ នោះគេបាន $A\cap C\subset B\cap D$

គេមាន $A\subset B$ និង $C\subset C$ នោះគេបាន $A\cap C\subset B\cap C$

$\therefore$ | បើ $A\subset B$ នោះគេបាន $A\cap C\subset B\cap C$ |

- តាមសំណួរ ( i ) គេមាន បើ $A\subset B$ និង $C\subset D$ នោះគេបាន $A\cup C\subset B\cup D$

គេមាន $A\subset B$ និង $C\subset C$ នោះគេបាន $A\cup C\subset B\cup C$

$\therefore$ | បើ $A\subset B$ នោះគេបាន $A\cup C\subset B\cup C$ |

iii. បើ $A\cap C\subset B\cap C$ តើគេបាន $A\subset B$ ឬទេ ?

( សម្រាយបញ្ជាក់ ដោយលើកឧទាហរណ៍ផ្ទុយ )

ឧទាហរណ៍ : គេមានបីសំណុំ $A=\{1,2,3\}$ , $B=\{2,3,5,6\}$ និង $C=\{2,4,6\}$

គេបាន $A\cap C=\{2\}$ , $B\cap C=\{2,6\}$

$\therefore$ | បើ $A\cap C\subset B\cap C$ គេមិនអាចទាញបានថា $A\subset B$ ទេ |

iv. បើ $A\cup C\subset B\cup C$ តើគេបាន $A\subset B$ ឬទេ ?

( សម្រាយបញ្ជាក់ ដោយលើកឧទាហរណ៍ផ្ទុយ )

ឧទាហរណ៍ : គេមានបីសំណុំ $A=\{3,4\}$ , $B=\{1,2,3\}$ និង $C=\{4,5,6\}$

គេបាន $A\cup C=\{3,4,5,6\}$ , $B\cup C=\{1,2,3,4,5,6\}$

$\therefore$ | បើ $A\cup C\subset B\cup C$ គេមិនអាចទាញបានថា $A\subset B$ ទេ |

v. បើ $A\cap C\subset B\cap C$ និង $A\cup C\subset B\cup C$ តើគេបាន $A\subset B$ ឬទេ ?

+ ករណីទី១ : បើ $x\in A$ និង $x\in C$

ក្នុងករណី $x\in A\cap C$

គេមាន $A\cap C\subset B\cap C$

នាំឱ្យ $x\in B\cap C \Leftrightarrow x\in B$ និង $x\in C$

$\Rightarrow x\in B$

នាំឱ្យ $A\subset B$

+ ករណីទី២ : បើ $x\in A$ និង $x\notin C$

ក្នុងករណី $x\in A\cup C$

គេមាន $A\cup C\subset B\cup C$

នាំឱ្យ $x\in B\cup C \Leftrightarrow x\in B$ ឬ $x\in C$

តែ $x\notin C$ នាំឱ្យ $x\in B$

នាំឱ្យ $A\subset B$

$\therefore$ | បើ $A\cap C\subset B\cap C$ និង $A\cup C\subset B\cup C$ គេបាន $A\subset B$ |

12. រក Dual នៃសមភាពខាងក្រោម :

i. $A\cup(A\cap B)=A$

- Dual នៃ $A\cup(A\cap B)=A$ គឺ $A\cap(A\cup B)=A$

$\therefore$ Dual នៃ $A\cup(A\cap B)=A$ គឺ $A\cap(A\cup B)=A$

ii. $(A\cap B)\cup(\overline{A}\cap B)\cup(A\cap\overline{B})\cup(\overline{A}\cap\overline{B})=U$

- Dual នៃ $(A\cap B)\cup(\overline{A}\cap B)\cup(A\cap\overline{B})\cup(\overline{A}\cap\overline{B})=U$ គឺ :

$(A\cup B)\cap(\overline{A}\cup B)\cap(A\cup\overline{B})\cap(\overline{A}\cup\overline{B})=\varnothing$

$\therefore$ Dual នៃ $(A\cap B)\cup(\overline{A}\cap B)\cup(A\cap\overline{B})\cup(\overline{A}\cap\overline{B})=U$ គឺ :

$(A\cup B)\cap(\overline{A}\cup B)\cap(A\cup\overline{B})\cap(\overline{A}\cup\overline{B})=\varnothing$

iii. $(U\cap A)\cup(B\cap A)=A$

- Dual នៃ $(U\cap A)\cup(B\cap A)=A$ គឺ $(\varnothing\cup A)\cap(B\cup A)=A$

$\therefore$ Dual នៃ $(U\cap A)\cup(B\cap A)=A$ គឺ $(\varnothing\cup A)\cap(B\cup A)=A$

iv. $(A\cap U)\cap(\varnothing\cup\overline{A})=\varnothing$

- Dual នៃ $(A\cap U)\cap(\varnothing\cup\overline{A})=\varnothing$ គឺ $(A\cup\varnothing)\cup(U\cap\overline{A})=U$

$\therefore$ Dual នៃ $(A\cap U)\cap(\varnothing\cup\overline{A})=\varnothing$ គឺ $(A\cup\varnothing)\cup(U\cap\overline{A})=U$

v. $(A\cup U)\cap(A\cap\varnothing)=\varnothing$

- Dual នៃ $(A\cup U)\cap(A\cap\varnothing)=\varnothing$ គឺ $(A\cap\varnothing)\cup(A\cup U)=U$

$\therefore$ Dual នៃ $(A\cup U)\cap(A\cap\varnothing)=\varnothing$ គឺ $(A\cap\varnothing)\cup(A\cup U)=U$

vi. $\overline{A\cup B\cup C}=\overline{A\cup C}\cap\overline{A\cup B}$

- Dual នៃ $\overline{A\cup B\cup C}=\overline{A\cup C}\cap\overline{A\cup B}$ គឺ $\overline{A\cap B\cap C}=\overline{A\cap C}\cup\overline{A\cap B}$

$\therefore$ Dual នៃ $\overline{A\cup B\cup C}=\overline{A\cup C}\cap\overline{A\cup B}$ គឺ $\overline{A\cap B\cap C}=\overline{A\cap C}\cup\overline{A\cap B}$

vii. $\overline{A\cap U}\cap A=\varnothing$

- Dual នៃ $\overline{A\cap U}\cap A=\varnothing$ គឺ $\overline{A\cup\varnothing}\cup A=U$

$\therefore$ Dual នៃ $\overline{A\cap U}\cap A=\varnothing$ គឺ $\overline{A\cup\varnothing}\cup A=U$

viii. $A\cup B=\overline{\overline{A}\cap\overline{B}}$

- Dual នៃ $A\cup B=\overline{\overline{A}\cap\overline{B}}$ គឺ $A\cap B=\overline{\overline{A}\cup\overline{B}}$

$\therefore$ Dual នៃ $A\cup B=\overline{\overline{A}\cap\overline{B}}$ គឺ $A\cap B=\overline{\overline{A}\cup\overline{B}}$

ix. $(A\cap U)\cap(B\cup C)=(A\cap B)\cup(A\cap C)$

- Dual នៃ $(A\cap U)\cap(B\cup C)=(A\cap B)\cup(A\cap C)$ គឺ :

$(A\cup\varnothing)\cup(B\cap C)=(A\cup B)\cap(A\cup C)$

$\therefore$ Dual នៃ $(A\cap U)\cap(B\cup C)=(A\cap B)\cup(A\cap C)$ គឺ :

$(A\cup\varnothing)\cup(B\cap C)=(A\cup B)\cap(A\cup C)$

x. $\overline{A}\cup\overline{B}\cup\overline{C}=\overline{A\cap B\cap C}$

- Dual នៃ $\overline{A}\cup\overline{B}\cup\overline{C}=\overline{A\cap B\cap C}$ គឺ $\overline{A}\cap\overline{B}\cap\overline{C}=\overline{A\cup B\cup C}$

$\therefore$ Dual នៃ $\overline{A}\cup\overline{B}\cup\overline{C}=\overline{A\cap B\cap C}$ គឺ $\overline{A}\cap\overline{B}\cap\overline{C}=\overline{A\cup B\cup C}$

13. គេឱ្យបីសំណុំ $A$ , $B$ , $C$ ។

i. បើ $A\cap C=B\cap C$ តើគេបាន $A=B$ ឬទេ ?

( សម្រាយបញ្ជាក់ ដោយលើកឧទាហរណ៍ផ្ទុយ )

ឧទាហរណ៍ : គេមានបីសំណុំ $A=\{a,d,e,k,l\}$ , $B=\{a,d,e,g,h,i\}$ និង $C=\{a,b,c,d,e,f\}$

គេបាន $A\cap C=\{a,d,e\}$ , $B\cap C=\{a,d,e\}$

គេសង្កេតឃើញថា $A\cap C=B\cap C=\{a,d,e\}$

តែគេមិនអាចទាញបានថា $A=B$ ទេ

$\therefore$ បើ $A\cap C=B\cap C$ គេមិនអាចទាញបានថា $A=B$ ទេ

ii. បើ $A\cup C=B\cup C$ តើគេបាន $A=B$ ឬទេ ?

( សម្រាយបញ្ជាក់ ដោយលើកឧទាហរណ៍ផ្ទុយ )

ឧទាហរណ៍ : គេមានបីសំណុំ $A=\{a,g,h,i\}$ , $B=\{a,d,e,g,h,i\}$ និង $C=\{a,b,c,d,e,f\}$

គេបាន $A \cup C = \{a,b,c,d,e,f,g,h,i\}$ , $B \cup C = \{a,b,c,d,e,f,g,h,i\}$

គេសង្កេតឃើញថា $A \cup C = B \cup C = \{a,b,c,d,e,f,g,h,i\}$

តែគេមិនអាចទាញបានថា $A = B$ ទេ

$\therefore$ បើ $A \cup C = B \cup C$ គេមិនអាចទាញបានថា $A = B$ ទេ

iii. បើ $A \cap C = B \cap C$ និង $A \cup C = B \cup C$ តើគេបាន $A = B$ ឬទេ ?

- គេស្រាយថា $A \subset B$

\+ ករណីទី១ : បើ $x \in A$ និង $x \in C$

ក្នុងករណី $x \in A \cap C$

គេមាន $A \cap C = B \cap C$

នាំឱ្យ $x \in B \cap C \Leftrightarrow x \in B$ និង $x \in C$

$\Rightarrow x \in B$

នាំឱ្យ $A \subset B$

\+ ករណីទី២ : បើ $x \in A$ និង $x \notin C$

ក្នុងករណី $x \in A \cup C$

គេមាន $A \cup C = B \cup C$

នាំឱ្យ $x \in B \cup C \Leftrightarrow x \in B$ ឬ $x \in C$

តែ $x \notin C$ នាំឱ្យ $x \in B$

នាំឱ្យ $A \subset B$

- គេស្រាយថា $B \subset A$

+ ករណីទី១ : បើ $x \in B$ និង $x \in C$

ក្នុងករណី $x \in B \cap C$

គេមាន $A \cap C = B \cap C$

នាំឱ្យ $x \in A \cap C \Leftrightarrow x \in A$ និង $x \in C$

$\Rightarrow x \in A$

នាំឱ្យ $B \subset A$

+ ករណីទី២ : បើ $x \in B$ និង $x \notin C$

ក្នុងករណី $x \in B \cup C$

គេមាន $A \cup C = B \cup C$

នាំឱ្យ $x \in A \cup C \Leftrightarrow x \in A$ ឬ $x \in C$

តែ $x \notin C$ នាំឱ្យ $x \in A$

នាំឱ្យ $B \subset A$

$\therefore$ បើ $A \cap C = B \cap C$ និង $A \cup C = B \cup C$ គេបាន $A = B$

14. ការស្ទង់មតិចំពោះនិស្សិតចំនួន 100 នាក់ឱ្យលទ្ធផលតាមស្ថិតិដូចខាងក្រោម :

32 នាក់រៀនគណិតវិទ្យា , 20 នាក់រៀនរូបវិទ្យា , 45 នាក់រៀនជីវវិទ្យា , 15 នាក់រៀនគណិតវិទ្យា និង ជីវវិទ្យា

7 នាក់រៀនគណិតវិទ្យា និង រូបវិទ្យា , 10 នាក់រៀនរូបវិទ្យា និង ជីវវិទ្យា , 30 នាក់មិនរៀនទាំងបីមុខវិជ្ជា ។

ក. រកចំនួននិស្សិតដែលរៀនទាំងបីមុខវិជ្ជា

- តាង $n(X)$ ជាចំនួននិស្សិតមិនរៀនទាំងបីមុខវិជ្ជា

តាមសម្មតិកម្មគេមាន :

- $n(U)=100$
- $n(X)=30$
- $n(M)=32$
- $n(Ph)=20$
- $n(B)=45$
- $n(M\cap B)=15$
- $n(M\cap Ph)=7$
- $n(Ph\cap B)=10$

គេបាន $n(M\cup B\cup Ph)=n(U)-n(X)=100-30=70$

តាមរូបមន្តគេបាន :

$$n(M\cup B\cup Ph)=n(M)+n(B)+n(Ph)-n(M\cap B)-n(M\cap Ph)-n(Ph\cap B)+n(M\cap B\cap Ph)$$

នាំឱ្យ $n(M\cap B\cap Ph)$ គឺ :

$$n(M\cap B\cap Ph)=n(M\cup B\cup Ph)-n(M)-n(B)-n(Ph)+n(M\cap B)+n(M\cap Ph)+n(Ph\cap B)$$

$$n(M\cap B\cap Ph)=70-32-45-20+15+7+10=5$$

$$\therefore \quad \boxed{n(M\cap B\cap Ph)=5}$$

ខ. រកចំនួននិស្សិតដែលរៀនតែពីរមុខវិជ្ជា

$n(M\cap B)=15$

$n(M\cap B)-n(M\cap B\cap Ph)=15-5=10$

$n(M\cap Ph)=7$

$n(M\cap Ph)-n(M\cap B\cap Ph)=7-5=2$

$n(Ph\cap B)=10$

$n(Ph\cap B)-n(M\cap B\cap Ph)=10-5=5$

ដូច្នេះ

10 នាក់ រៀនតែគណិត និង ជីវៈ

2 នាក់ រៀនតែគណិត និង រូប

5 នាក់ រៀនតែរូប និង ជីវៈ

គ. រកចំនួននិស្សិតដែលរៀនតែមួយមុខវិជ្ជា

$n(M)=32$

$n(M)-n(M\cap Ph)-n(M\cap B)+n(M\cap B\cap Ph)=32-7-15+5=15$

$n(Ph)=20$

$n(Ph)-n(M\cap Ph)-n(Ph\cap B)+n(M\cap B\cap Ph)=20-7-10+5=8$

$n(B)=45$

$n(B)-n(M\cap B)-n(Ph\cap B)+n(M\cap B\cap Ph)=45-15-10+5=25$

ដូច្នេះ

15 នាក់ រៀនតែគណិត

8 នាក់ រៀនតែរូប

25 នាក់ រៀនតែជីវៈ

Venn diagram




15. ការស្ទង់មតិចំពោះប្រជាជន 60 នាក់ឱ្យលទ្ធផលតាមស្ថិតិដូចខាងក្រោម :

25 នាក់អានទស្សនាវដ្ដីប្រជាប្រិយ , 26 នាក់អានទស្សនាវដ្ដីកុលធីតា , 26 នាក់អានទស្សនាវដ្ដីអង្គរធំ

9 នាក់អានទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីកុលធីតា , 11នាក់អានទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីអង្គរធំ

8 នាក់អានទស្សនាវដ្ដីកុលធីតា និង ទស្សនាវដ្ដីអង្គរធំ , 8 នាក់មិនអានទាំងបីទស្សនាវដ្ដី ។

ក. រកចំនួនប្រជាជនដែលអានទាំងបីទស្សនាវដ្ដី

- តាង $n(X)$ ជាចំនួនអ្នកមិនអានទាំងបីទស្សនាវដ្ដី

$n(B)$ ជាចំនួនអ្នកអានទស្សនាវដ្ដីប្រជាប្រិយ

$n(K)$ ជាចំនួនអ្នកអានទស្សនាវដ្ដីកុលធីតា

$n(A)$ ជាចំនួនអ្នកអានទស្សនាវដ្ដីអង្គរធំ

តាមសម្មតិកម្មគេមាន :

- $n(U)=60$
- $n(X)=8$
- $n(B)=25$
- $n(K)=26$
- $n(A)=26$
- $n(B\cap K)=9$
- $n(B\cap A)=11$
- $n(K\cap A)=8$

គេបាន $n(B\cup K\cup A)=n(U)-n(X)=60-8=52$

តាមរូបមន្តគេបាន :

$$n(B\cup K\cup A)=n(B)+n(K)+n(A)-n(B\cap K)-n(B\cap A)-n(K\cap A)+n(B\cap K\cap A)$$

នាំឱ្យ $n(B\cap K\cap A)$ គឺ :

$$n(B\cap K\cap A)=n(B\cup K\cup A)-n(B)-n(K)-n(A)+n(B\cap K)+n(B\cap A)+n(K\cap A)$$

$$n(B\cap K\cap A)=52-25-26-26+9+11+8=3$$

$$\therefore \quad \boxed{n(B\cap K\cap A)=3}$$

ខ. រកចំនួនប្រជាជនដែលអានតែពីរទស្សនាវដ្ដី

$n(B\cap K)=9$

$n(B\cap K)-n(B\cap K\cap A)=9-3=6$

$n(B\cap A)=11$

$n(B\cap A)-n(B\cap K\cap A)=11-3=8$

$n(K\cap A)=8$

$n(K\cap A)-n(B\cap K\cap A)=8-3=5$

ដូច្នេះ

| |
|---|
| 6 នាក់ អានតែទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីកុលធីតា |
| 8 នាក់ អានតែទស្សនាវដ្ដីប្រជាប្រិយ និង ទស្សនាវដ្ដីអង្គរធំ |
| 5 នាក់ អានតែទស្សនាវដ្ដីកុលធីតា និង ទស្សនាវដ្ដីអង្គរធំ |

គ. រកចំនួនប្រជាជនដែលអានតែមួយទស្សនាវដ្ដី

$n(B)=25$

$n(B)-n(B\cap K)-n(B\cap A)+n(B\cap K\cap A)=25-9-11+3=8$

$n(K)=26$

$n(K)-n(B\cap K)-n(K\cap A)+n(B\cap K\cap A)=26-9-8+3=12$

$n(A)=26$

$n(A)-n(B\cap A)-n(K\cap A)+n(B\cap K\cap A)=26-11-8+3=10$

ដូច្នេះ

| |
|---|
| 8 នាក់ អានតែទស្សនាវដ្ដីប្រជាប្រិយ |
| 12 នាក់ អានតែទស្សនាវដ្ដីកុលធីតា |
| 10 នាក់ អានតែទស្សនាវដ្ដីអង្គរធំ |

Venn diagram




16. គេឱ្យសំណុំ $A=\{1,2,3,4,5\}$ ។ រកថ្នាក់ $\mathcal{A}$ ដែល :

ក. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមិនមានធាតុ 2 និង 4 ។

- ដោយ $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមិនមានធាតុ 2 និង 4

$\therefore$ $\boxed{\mathcal{A}=\{\varnothing,\{1\},\{3\},\{5\},\{1,3\},\{1,5\},\{3,5\},\{1,3,5\}\}}$

ខ. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានផលបូកធាតុទាំងអស់ស្មើនឹង 5

- ដោយ $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានផលបូកធាតុទាំងអស់ស្មើនឹង 5

ដូច្នេះ គេបាន $\mathcal{A}=\{\{5\},\{1,4\},\{2,3\}\}$

$\therefore$ $\boxed{\mathcal{A}=\{\{5\},\{1,4\},\{2,3\}\}}$

គ. $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានបួនធាតុ

- ដោយ $\mathcal{A}$ ថ្នាក់នៃសំណុំរងនៃ $A$ ដែលមានបួនធាតុ

ដូច្នេះ គេបាន $\mathcal{A} = \{\{1,2,3,4\},\{1,2,3,5\}\{1,2,4,5\},\{1,3,4,5\},\{2,3,4,5\}\}$

$\therefore$ $\boxed{\mathcal{A} = \{\{1,2,3,4\},\{1,2,3,5\}\{1,2,4,5\},\{1,3,4,5\},\{2,3,4,5\}\}}$

17. រក Power set $\mathcal{P}(A)$ ដែល :

ក. $A=\{a,b,c\}$

- គេមាន សំណុំ $A=\{a,b,c\}$

នោះគេបាន Power set $\mathcal{P}(A)$ គឺ $\mathcal{P}(A)=\{\varnothing,\{a\},\{b\},\{c\},\{a,b\},\{a,c\},\{b,c\},\{a,b,c\}\}$

$\therefore$ $\boxed{\mathcal{P}(A)=\{\varnothing,\{a\},\{b\},\{c\},\{a,b\},\{a,c\},\{b,c\},\{a,b,c\}\}}$

ខ. $A=\{1,2,3,4\}$

- គេមាន សំណុំ $A=\{1,2,3,4\}$

នោះគេបាន Power set $\mathcal{P}(A)$ គឺ :

$$\boxed{\mathcal{P}(A)=\{\varnothing,\{1\},\{2\},\{3\},\{4\},\{1,2\},\{1,3\},\{1,4\},\{2,3\},\{2,4\},\{3,4\},\{1,2,3\},\{1,2,4\},\{1,3,4\},\{2,3,4\},\{1,2,3,4\}\}}$$

គ. $A=\{a,b,c,d,e\}$

- គេមាន សំណុំ $A=\{a,b,c,d,e\}$

នោះគេបាន Power set $\mathcal{P}(A)$ គឺ

$$\mathcal{P}(A)=\{\ \varnothing,\{a\},\{b\},\{c\},\{d\},\{e\},\{a,b\},\{a,c\},\{a,d\},\{a,e\},\{b,c\},\{b,d\},\{b,e\},\{c,d\},\{c,e\},\{d,e\},$$
$$\{a,b,c\},\{a,b,d\},\{a,b,e\},\{a,c,d\},\{a,c,e\},\{a,d,e\},\{b,c,d\},\{b,c,e\},\{b,d,e\},\{c,d,e\},$$
$$\{a,b,c,d\},\{a,b,c,e\},\{a,b,d,e\},\{a,c,d,e\},\{b,c,d,e\},\{a,b,c,d,e\}\ \}$$

18\. សិក្សាសុពលភាព ( validity ) នៃ Argument ខាងក្រោម :

$S_1$ : និស្សិតទាំងអស់សុទ្ធតែជាមនុស្សឧស្សាហ៍

$S_2$ : គ្មានអ្នកក្រណាម្នាក់ជានិស្សិត

---

$S$ : មនុស្សឧស្សាហ៍សុទ្ធតែមិនមែនជាអ្នកក្រ




តាមដ្យាក្រាមវិន ខាងលើ គេបាន Argument នេះ invalid

19\. បង្ហាញថា :

i. $1^2+2^2+3^2+\cdots\cdots+n^2=\dfrac{n(n+1)(2n+1)}{6}$

\+ ចំពោះ $n=1$ គេបាន $1^2=\dfrac{1\times 2\times 3}{6}\Leftrightarrow 1=1$ ពិត

+ ចំពោះ $n=2$ គេបាន $1^2+2^2=\dfrac{2\times3\times5}{6} \Leftrightarrow 5=5$ ពិត

ឧបមាថាពិតដល់ $n$ គឺ $1^2+2^2+3^2+\cdots\cdots+n^2=\dfrac{n(n+1)(2n+1)}{6}$

គេនឹងស្រាយថាពិតដល់ $n+1$ គឺ

$$1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=\frac{(n+1)\times[(n+1)+1]\times[2(n+1)+1]}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=\frac{(n+1)(n+2)(2n+3)}{6}$$

គេមាន $1^2+2^2+3^2+\cdots\cdots+n^2=\dfrac{n(n+1)(2n+1)}{6}$

$$\Rightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=\frac{n(n+1)(2n+1)}{6}+(n+1)^2$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=\frac{n(n+1)(2n+1)+6(n+1)^2}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=(n+1)\times\frac{n(2n+1)+6(n+1)}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=(n+1)\times\frac{2n^2+n+6n+6}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=(n+1)\times\frac{2n^2+7n+6}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=(n+1)\times\frac{2n^2+4n+3n+6}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=(n+1)\times\frac{2n(n+2)+3(n+2)}{6}$$

$$\Leftrightarrow 1^2+2^2+3^2+\cdots\cdots+n^2+(n+1)^2=\frac{(n+1)(n+2)(2n+3)}{6}$$

$$\therefore \quad \boxed{1^2+2^2+3^2+\cdots\cdots+n^2=\frac{n(n+1)(2n+1)}{6}}$$

ii. $1+4+7+\cdots\cdots+(3n-2)=\dfrac{n(3n-1)}{2}$

+ ចំពោះ $n=1$ គេបាន $1=\dfrac{1\times 2}{2} \Leftrightarrow 1=1$ ពិត

+ ចំពោះ $n=2$ គេបាន $1+4=\dfrac{2\times 5}{2} \Leftrightarrow 5=5$ ពិត

ឧបមាថាពិតដល់ $n$ គឺ $1+4+7+\cdots\cdots+(3n-2)=\dfrac{n(3n-1)}{2}$

គេនឹងស្រាយថាពិតដល់ $n+1$ គឺ

$$1+4+7+\cdots\cdots+(3n-2)+[3(n+1)-2]=\frac{(n+1)\times[3(n+1)-1]}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{(n+1)(3n+2)}{2}$$

គេមាន $1+4+7+\cdots\cdots+(3n-2)=\dfrac{n(3n-1)}{2}$

$$\Rightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{n(3n-1)}{2}+(3n+1)$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{n(3n-1)+2(3n+1)}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{3n^2-n+6n+2}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{3n^2+5n+2}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{3n^2+3n+2n+2}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{3n(n+1)+2(n+1)}{2}$$

$$\Leftrightarrow 1+4+7+\cdots\cdots+(3n-2)+(3n+1)=\frac{(n+1)(3n+2)}{2}$$

$$\therefore \quad \boxed{1+4+7+\cdots\cdots+(3n-2)=\frac{n(3n-1)}{2}}$$

iii. $\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}=\frac{n}{2n+1}$

+ ចំពោះ $n=1$ គេបាន $\frac{1}{1.3}=\frac{1}{3}\Leftrightarrow\frac{1}{3}=\frac{1}{3}$ ពិត

+ ចំពោះ $n=2$ គេបាន $\frac{1}{1.3}+\frac{1}{3.5}=\frac{2}{5}\Leftrightarrow\frac{5+1}{15}=\frac{2}{5}\Leftrightarrow\frac{6}{15}=\frac{2}{5}\Leftrightarrow\frac{2}{5}=\frac{2}{5}$ ពិត

ឧបមាថាពិតដល់ $n$ គឺ $\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}=\frac{n}{2n+1}$

គេនឹងស្រាយថាពិតដល់ $n+1$ គឺ

$$\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{[2(n+1)-1]\times[2(n+1)+1]}=\frac{n+1}{2(n+1)+1}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{n+1}{2n+3}$$

គេមាន $\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}=\frac{n}{2n+1}$

$$\Rightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{n}{2n+1}+\frac{1}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{n(2n+3)+1}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{2n^2+3n+1}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{2n^2+2n+n+1}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{2n(n+1)+(n+1)}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{(n+1)(2n+1)}{(2n+1)(2n+3)}$$

$$\Leftrightarrow\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}+\frac{1}{(2n+1)(2n+3)}=\frac{n+1}{2n+3}$$

$\therefore$ $\boxed{\frac{1}{1.3}+\frac{1}{3.5}+\cdots\cdots+\frac{1}{(2n-1)(2n+1)}=\frac{n}{2n+1}}$

iv. $n!\geq 2^n$ , for $\forall n\geq 4$

+ ចំពោះ $n=4$ គេបាន $4!\geq 2^4 \Leftrightarrow 24\geq 16$ ពិត

+ ចំពោះ $n=5$ គេបាន $5!\geq 2^5 \Leftrightarrow 120\geq 32$ ពិត

ឧបមាថាពិតដល់ $n$ គឺ $n!\geq 2^n$

គេនឹងស្រាយថាពិតដល់ $n+1$ គឺ $(n+1)!\geq 2^{n+1}$

គេមាន $n!\geq 2^n$

$\Rightarrow n!\times(n+1)\geq 2^n\times(n+1)$

$\Leftrightarrow (n+1)!\geq 2^n\times(n+1)$

ដោយចំពោះ $\forall n\geq 4$ គេបាន $(n+1)\geq 2$

$\Rightarrow (n+1)!\geq 2^n\times 2$

$\Leftrightarrow (n+1)!\geq 2^{n+1}$

$\therefore$ $\boxed{n!\geq 2^n \text{ , for } \forall n\geq 4}$

20. គេឱ្យពីរសំណុំ $A$ , $B$ ។

គេបានផលសងឆ្លុះនៃ $A$ និង $B$ កំណត់សរសេរដោយ : $A\Delta B=(A\cup B)\setminus(A\cap B)$ ។

a) Given $A=\{1,2,3,4,5,6\}$ , $B=\{4,5,6,7,8,9\}$ , $C=\{1,3,5,7,9\}$ , $D=\{2,3,5,7,8\}$

រក $A\Delta B$ , $B\Delta C$ , $C\Delta D$ , $A\Delta D$ , $A\cap(B\Delta D)$ , $(A\cap B)\Delta(A\cap D)$

- $A\Delta B = (A \cup B) \setminus (A \cap B)$

$A \cup B = \{1,2,3,4,5,6,7,8,9\}$ , $A \cap B = \{4,5,6\}$

$\therefore$ $\boxed{A\Delta B = \{1,2,3,7,8,9\}}$

- $B\Delta C = (B \cup C) \setminus (B \cap C)$

$B \cup C = \{1,3,4,5,6,7,8,9\}$ , $B \cap C = \{5,7,9\}$

$\therefore$ $\boxed{B\Delta C = \{1,3,4,6,8\}}$

- $C\Delta D = (C \cup D) \setminus (C \cap D)$

$C \cup D = \{1,2,3,5,7,8,9\}$ , $C \cap D = \{3,5,7\}$

$\therefore$ $\boxed{C\Delta D = \{1,2,8,9\}}$

- $A\Delta D = (A \cup D) \setminus (A \cap D)$

$A \cup D = \{1,2,3,4,5,6,7,8\}$ , $A \cap D = \{2,3,5\}$

$\therefore$ $\boxed{A\Delta D = \{1,4,6,7,8\}}$

- $A \cap (B\Delta D)$

គេមាន $A = \{1,2,3,4,5,6\}$

$B\Delta D = (B \cup D) \setminus (B \cap D)$

$B \cup D = \{2,3,4,5,6,7,8,9\}$ , $B \cap D = \{5,7,8\}$

$\Rightarrow B\Delta D = \{2,3,4,6,9\}$

$\Rightarrow A \cap (B\Delta D) = \{2,3,4,6\}$

$\therefore$ $$\boxed{A\cap(B\Delta D)=\{2,3,4,6\}}$$

- $(A\cap B)\Delta(A\cap D)=[(A\cap B)\cup(A\cap D)]\setminus[(A\cap B)\cap(A\cap D)]$

$A\cap B=\{4,5,6\}$ , $A\cap D=\{2,3,5\}$

$\Rightarrow (A\cap B)\cup(A\cap D)=\{2,3,4,5,6\}$ , $(A\cap B)\cap(A\cap D)=\{5\}$

$\therefore$ $$\boxed{(A\cap B)\Delta(A\cap D)=\{2,3,4,6\}}$$

b) បង្ហាញថា : $A\Delta B=(A-B)\cup(B-A)$

$\forall x: x\in A\Delta B \Leftrightarrow (x\in A\wedge x\notin B)\vee(x\in B\wedge x\notin A)$

$\Leftrightarrow x\in(A\setminus B)\vee x\in(B\setminus A)$

$\Leftrightarrow x\in(A\setminus B)\cup(B\setminus A)$

$\therefore$ $$\boxed{A\Delta B=(A-B)\cup(B-A)}$$

ꕥꕥꕥ 🕮 ꕥꕥꕥ

# ទំនាក់ទំនងទ្វេធាតុ - អនុគមន៍ - អនុវត្តន៍

## ផ្នែកប្រធានលំហាត់

1. ក្នុងចំណោមទំនាក់ទំនងទ្វេធាតុខាងក្រោម :

   តើទំនាក់ទំនងមួយណាជាទំនាក់ទំនងទ្វេធាតុពីសំណុំ $A=\{a,b,c\}$ ទៅសំណុំ $B=\{1,2\}$

   i. $\mathcal{R}_1=\{(a,1),(a,2),(c,2)\}$

   ii. $\mathcal{R}_2=\{(a,2),(1,a)\}$

   iii. $\mathcal{R}_3=\{(c,1),(c,2),(c,3)\}$

   iv. $\mathcal{R}_4=\{(1,a),(2,b),(2,c)\}$

   v. $\mathcal{R}_5=\{(a,2),(b,2)\}$

   vi. $\mathcal{R}_6=\varnothing$

2. គេឱ្យពីរសំណុំ $A=\{a,b,c\}$ , $B=\{1,2\}$ ។ តើមានប៉ុន្មានទំនាក់ទំនងទ្វេធាតុពីសំណុំ $A$ ទៅសំណុំ $B$ ។

3. រក $\mathcal{R}$ ដោយដឹងថា $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុកំណត់លើ $A=\{1,2,3,4\}$ ដោយ $x\mathcal{R}y \Leftrightarrow x<y$ ។

   រួចរកទំនាក់ទំនងទ្វេធាតុច្រាសនៃ $\mathcal{R}$ ។

   តាង $\mathcal{R}$ ដោយ Coordinate diagram , Matrix នៃទំនាក់ទំនង និង Arrow diagram ។

4. គេឱ្យសំណុំ $A=\{1,2,3,4,6\}$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុកំណត់លើ $A$ ដោយ $x\mathcal{R}y \Leftrightarrow x|y$ ។

   ក. សរសេរ $\mathcal{R}$ ជាសំណុំនៃគូមានលំដាប់ ។

   ខ. តាង $\mathcal{R}$ ដោយ Coordinate diagram និង គូ Directed graph នៃ $\mathcal{R}$ ។

   គ. រកទំនាក់ទំនងទ្វេធាតុច្រាស $\mathcal{R}^{-1}$ នៃ $\mathcal{R}$ ។

5. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}$ កំណត់ដោយ $a\mathcal{R}b \Leftrightarrow a^2+a=b^2+b$ ។

   ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

6. គេឱ្យអនុវត្តន៍ $f:E\to F$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ កំណត់ដោយ $x\mathcal{R}x' \Leftrightarrow f(x)=f(x')$

   ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

7. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}\times\mathbb{N}$ កំណត់ដោយ $(a,b)\mathcal{R}(c,d)\Leftrightarrow a+d=b+c$ ។

   ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

8. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}\times\mathbb{Z}^*$ កំណត់ដោយ $(a,b)\mathcal{R}(c,d)\Leftrightarrow a.d=b.c$ ។

   ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

9. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}$ កំណត់ដោយ $a\mathcal{R}b \Leftrightarrow a+b$ ជាចំនួនគូ ។

   ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

10. គេឱ្យអនុគមន៍ប្រកាន់ $f:\mathbb{R}\to\mathbb{R}$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}$ កំណត់ដោយ :

    $x\mathcal{R}x' \Leftrightarrow f(x)\le f(x')$ ។ ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

11. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}$ កំណត់ដោយ $a\mathcal{R}b \Leftrightarrow a\le b$ ។

    ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

12. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}^*$ កំណត់ដោយ $a\mathcal{R}b \Leftrightarrow a|b$ ។

    ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

13. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}\times\mathbb{R}$ កំណត់ដោយ $(a,b)\mathcal{R}(c,d)\Leftrightarrow a\le c\wedge b\le d$ ។

    ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

14. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}\times\mathbb{R}$ កំណត់ដោយ $(a,b)\mathcal{R}(c,d)\Leftrightarrow [a<c\vee(a=c\wedge b\le d)]$

    ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

15. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x\mathcal{R}y \Leftrightarrow x+\frac{1}{x}=y+\frac{1}{y}$ ។

    ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

16. គេឱ្យ $A$ ជាសំណុំរងនៃសំណុំ $E$ ។លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$X \mathcal{R} Y \Leftrightarrow A \cap X = A \cap Y$ ។ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

## ផ្នែកដំណោះស្រាយ

1. ក្នុងចំណោមទំនាក់ទំនងទ្វេធាតុខាងក្រោម :

តើទំនាក់ទំនងមួយណាជាទំនាក់ទំនងទ្វេធាតុពីសំណុំ $A=\{a,b,c\}$ ទៅសំណុំ $B=\{1,2\}$

i. $\mathcal{R}_1=\{(a,1),(a,2),(c,2)\}$

ii. $\mathcal{R}_2=\{(a,2),(1,a)\}$

iii. $\mathcal{R}_3=\{(c,1),(c,2),(c,3)\}$

iv. $\mathcal{R}_4=\{(1,a),(2,b),(2,c)\}$

v. $\mathcal{R}_5=\{(a,2),(b,2)\}$

vi. $\mathcal{R}_6=\varnothing$

$\therefore$ $\mathcal{R}_1$ , $\mathcal{R}_5$ , $\mathcal{R}_6$ ជាទំនាក់ទំនងទ្វេធាតុពីសំណុំ $A$ ទៅ $B$

$\mathcal{R}_2$ , $\mathcal{R}_3$ , $\mathcal{R}_4$ មិនមែនជាទំនាក់ទំនងទ្វេធាតុពីសំណុំ $A$ ទៅ $B$ ទេ

2. គេឱ្យពីរសំណុំ $A=\{a,b,c\}$ , $B=\{1,2\}$ ។តើមានប៉ុន្មានទំនាក់ទំនងទ្វេធាតុពីសំណុំ $A$ ទៅសំណុំ $B$

ទំនាក់ទំនងទ្វេធាតុពីសំណុំ $A$ ទៅសំណុំ $B$ មានចំនួន 6 គឺ

$\mathcal{R}=\{(a,1),(a,2),(b,1),(b,2),(c,1),(c,2)\}$

$$\therefore \quad \boxed{\mathcal{R} = \{(a,1),(a,2),(b,1),(b,2),(c,1),(c,2)\}}$$

3\. រក $\mathcal{R}$ ដោយដឹងថា $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុកំណត់លើ $A=\{1,2,3,4\}$ ដោយ $x\,\mathcal{R}\,y \Leftrightarrow x<y$ ។ រួចរកទំនាក់ទំនងទ្វេធាតុច្រាសនៃ $\mathcal{R}$ ។

គាង $\mathcal{R}$ ដោយ Coordinate diagram , Matrix នៃទំនាក់ទំនង និង Arrow diagram ។

ទំនាក់ទំនងទ្វេធាតុកំណត់លើ $A=\{1,2,3,4\}$ គឺ $\mathcal{R} = \{(1,2),(1,3),(1,4),(2,3),(2,4),(3,4)\}$

ទំនាក់ទំនងទ្វេធាតុច្រាសនៃ $\mathcal{R}$ គឺ $\mathcal{R}^{-1} = \{(2,1),(3,1),(4,1),(3,2),(4,2),(4,3)\}$

Coordinate diagram




Matrix

| | 1 | 2 | 3 | 4 |
|---|---|---|---|---|
| 1 | 0 | 1 | 1 | 1 |
| 2 | 0 | 0 | 1 | 1 |
| 3 | 0 | 0 | 0 | 1 |
| 4 | 0 | 0 | 0 | 0 |

Arrow diagram



4. គេឱ្យសំណុំ $A=\{1,2,3,4,6\}$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុកំណត់លើ $A$ ដោយ $x\,\mathcal{R}\,y \Leftrightarrow x|y$ ។

ក. សរសេរ $\mathcal{R}$ ជាសំណុំនៃគូមានលំដាប់ ។

$\therefore$ $\mathcal{R}=\{(1,1),(2,2),(3,3),(4,4),(6,6),(1,2),(1,3),(1,4),(1,6),(2,4),(2,6),(3,6)\}$

ខ. តាង $\mathcal{R}$ ដោយ Coordinate diagram និង គូ Directed graph នៃ $\mathcal{R}$ ។

Coordinate diagram




Directed graph



គ. រកទំនាក់ទំនងទ្វេធាតុច្រាស $\mathcal{R}^{-1}$ នៃ $\mathcal{R}$

ទំនាក់ទំនងទ្វេធាតុច្រាស $\mathcal{R}^{-1}$ នៃ $\mathcal{R}$ គឺ

$\mathcal{R}^{-1}=\{(1,1),(2,2),(3,3),(4,4),(6,6),(2,1),(3,1),(4,1),(6,1),(4,2),(6,2),(6,3)\}$

$\therefore$ $\boxed{\mathcal{R}^{-1}=\{(1,1),(2,2),(3,3),(4,4),(6,6),(2,1),(3,1),(4,1),(6,1),(4,2),(6,2),(6,3)\}}$

5. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}$ កំណត់ដោយ $a\mathcal{R}b \Leftrightarrow a^2+a=b^2+b$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x\in\mathbb{Z}\ :\ x^2+x=x^2+x \Leftrightarrow x\mathcal{R}x$

លក្ខណៈឆ្លុះ $\forall x,y\in\mathbb{Z}\ :\ x\mathcal{R}y \Leftrightarrow x^2+x=y^2+y$

$$\Leftrightarrow y^2+y=x^2+x$$

$$\Leftrightarrow y\mathcal{R}x$$

លក្ខណៈឆ្លុះស្មើ $\forall x,y\in\mathbb{Z}\ :\ x\mathcal{R}y \wedge y\mathcal{R}x$

$$\Leftrightarrow \begin{cases} x^2+x=y^2+y \\ y^2+y=x^2+x \end{cases}$$

$$\Leftrightarrow x^2+x=y^2+y$$

$$\Leftrightarrow x^2-y^2+x-y=0$$

$$\Leftrightarrow (x-y)(x+y)+(x-y)=0$$

$$\Leftrightarrow (x-y)(x+y+1)=0$$

$$\Rightarrow \left[\begin{array}{l} x-y=0 \\ x+y+1=0 \end{array}\right.$$

$$\Leftrightarrow \left[\begin{array}{l} x = y \\ x = -(y+1) \end{array}\right.$$

$$\Rightarrow x = y$$

លក្ខណៈឆ្លង $\forall x, y, z \in \mathbb{Z} \ : \ x \mathcal{R} y \wedge y \mathcal{R} z$

$$\Leftrightarrow \begin{cases} x^2 + x = y^2 + y \\ y^2 + y = z^2 + z \end{cases}$$

$$\Leftrightarrow x^2 + x = z^2 + z$$

$$\Leftrightarrow x \mathcal{R} z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}$

6. គេឱ្យអនុវត្តន៍ $f: E \to F$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ កំណត់ដោយ $x \mathcal{R} x' \Leftrightarrow f(x) = f(x')$

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x \in E \ : \ f(x) = f(x) \Leftrightarrow x \mathcal{R} x$

លក្ខណៈឆ្លុះ $\forall x, y \in E \ : \ x \mathcal{R} y \Leftrightarrow f(x) = f(y)$

$$\Leftrightarrow f(y) = f(x)$$

$$\Leftrightarrow y \mathcal{R} x$$

លក្ខណៈឆ្លុះស្មើ $\forall x, y \in E \ : \ x \mathcal{R} y \wedge y \mathcal{R} x$

$$\Leftrightarrow \begin{cases} f(x) = f(y) \\ f(y) = f(x) \end{cases}$$

$$\not\Rightarrow x = y$$

លក្ខណៈឆ្លង $\forall x, y, z \in E \ : \ x \mathcal{R} y \wedge y \mathcal{R} z$

$$\Leftrightarrow \begin{cases} f(x) = f(y) \\ f(y) = f(z) \end{cases}$$

$$\Leftrightarrow f(x) = f(z)$$

$$\Leftrightarrow x \mathcal{R} z$$

$\therefore$ | $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះស្មើទេ |

7. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N} \times \mathbb{N}$ កំណត់ដោយ $(a,b)\mathcal{R}(c,d) \Leftrightarrow a + d = b + c$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall (x_1, x_2) \in \mathbb{N} \times \mathbb{N} \ : \ x_1 + x_2 = x_2 + x_1 \Leftrightarrow (x_1, x_2) \mathcal{R} (x_1, x_2)$

លក្ខណៈឆ្លុះ $\forall (x_1, x_2), (y_1, y_2) \in \mathbb{N} \times \mathbb{N} \ : \ (x_1, x_2) \mathcal{R} (y_1, y_2) \Leftrightarrow x_1 + y_2 = x_2 + y_1$

$$\Leftrightarrow y_2 + x_1 = y_1 + x_2 \Leftrightarrow y_1 + x_2 = y_2 + x_1$$

$$\Leftrightarrow (y_1, y_2) \mathcal{R} (x_1, x_2)$$

លក្ខណៈឆ្លុះស្មើ $\forall (x_1, x_2), (y_1, y_2) \in \mathbb{N} \times \mathbb{N} \ : \ (x_1, x_2) \mathcal{R} (y_1, y_2) \wedge (y_1, y_2) \mathcal{R} (x_1, x_2)$

$$\Leftrightarrow \begin{cases} x_1 + y_2 = x_2 + y_1 \\ y_1 + x_2 = y_2 + x_1 \end{cases}$$

$$\Leftrightarrow x_1 + y_2 = x_2 + y_1$$

$$\not\Rightarrow \begin{cases} x_1 = y_1 \\ x_2 = y_2 \end{cases}$$

លក្ខណៈឆ្លង $\forall(x_1,x_2),(y_1,y_2),(z_1,z_2)\in\mathbb{N}\times\mathbb{N}$ :

$(x_1,x_2)\,\mathcal{R}\,(y_1,y_2)\wedge(y_1,y_2)\,\mathcal{R}\,(z_1,z_2)$

$\Leftrightarrow\begin{cases}x_1+y_2=x_2+y_1\\y_1+z_2=y_2+z_1\end{cases}$

$\Leftrightarrow\begin{cases}x_1-x_2=y_1-y_2\\y_1-y_2=z_1-z_2\end{cases}$

$\Leftrightarrow x_1-x_2=z_1-z_2$

$\Leftrightarrow x_1+z_2=x_2+z_1$

$\Leftrightarrow (x_1,x_2)\,\mathcal{R}\,(z_1,z_2)$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះស្មើទេ

8. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}\times\mathbb{Z}^*$ កំណត់ដោយ $(a,b)\,\mathcal{R}\,(c,d)\Leftrightarrow a.d=b.c$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall(x_1,x_2)\in\mathbb{Z}\times\mathbb{Z}^*$ : $x_1.x_2=x_2.x_1\Leftrightarrow(x_1,x_2)\,\mathcal{R}\,(x_1,x_2)$

លក្ខណៈឆ្លុះ $\forall(x_1,x_2),(y_1,y_2)\in\mathbb{Z}\times\mathbb{Z}^*$ : $(x_1,x_2)\,\mathcal{R}\,(y_1,y_2)\Leftrightarrow x_1.y_2=x_2.y_1$

$\Leftrightarrow y_2.x_1=y_1.x_2\Leftrightarrow y_1.x_2=y_2.x_1$

$\Leftrightarrow (y_1,y_2)\,\mathcal{R}\,(x_1,x_2)$

លក្ខណៈឆ្លុះស្មើ $\forall(x_1,x_2),(y_1,y_2)\in\mathbb{Z}\times\mathbb{Z}^*$ : $(x_1,x_2)\,\mathcal{R}\,(y_1,y_2)\wedge(y_1,y_2)\,\mathcal{R}\,(x_1,x_2)$

$\Leftrightarrow\begin{cases}x_1.y_2=x_2.y_1\\y_1.x_2=y_2.x_1\end{cases}$

$\Leftrightarrow x_1.y_2 = x_2.y_1 \not\Rightarrow \begin{cases} x_1 = y_1 \\ x_2 = y_2 \end{cases}$

លក្ខណៈឆ្លង $\forall (x_1, x_2), (y_1, y_2), (z_1, z_2) \in \mathbb{Z} \times \mathbb{Z}^*$ :

$(x_1, x_2) \mathcal{R} (y_1, y_2) \wedge (y_1, y_2) \mathcal{R} (z_1, z_2)$

$\Leftrightarrow \begin{cases} x_1.y_2 = x_2.y_1 \\ y_1.z_2 = y_2.z_1 \end{cases}$

$\Leftrightarrow \begin{cases} \dfrac{x_1}{x_2} = \dfrac{y_1}{y_2} \\ \dfrac{y_1}{y_2} = \dfrac{z_1}{z_2} \end{cases}$

$\Leftrightarrow \dfrac{x_1}{x_2} = \dfrac{z_1}{z_2}$

$\Leftrightarrow x_1.z_2 = x_2.z_1$

$\Leftrightarrow (x_1, x_2) \mathcal{R} (z_1, z_2)$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះស្មើទេ

9. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}$ កំណត់ដោយ $a \mathcal{R} b \Leftrightarrow a + b$ ជាចំនួនគូ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x \in \mathbb{N}$ : $x + x$ ជាចំនួនគូ ( ព្រោះ $x + x = 2x$ ) $\Leftrightarrow x \mathcal{R} x$

លក្ខណៈឆ្លុះ $\forall x, y \in \mathbb{N}$ : $x \mathcal{R} y \Leftrightarrow x + y$ ជាចំនួនគូ

$\Leftrightarrow y + x$ ជាចំនួនគូ

$\Leftrightarrow y \mathcal{R} x$

លក្ខណៈឆ្លុះស្មើ $\forall x,y\in\mathbb{N}\ :\ x\mathcal{R}\,y\ \wedge\ y\mathcal{R}\,x$

$\Leftrightarrow x+y$ ជាចំនួនគូ $\wedge$ $y+x$ ជាចំនួនគូ

$\nRightarrow\ x=y$

លក្ខណៈឆ្លង $\forall x,y,z\in\mathbb{N}\ :\ x\mathcal{R}\,y\ \wedge\ y\mathcal{R}\,z$

$\Leftrightarrow x+y$ ជាចំនួនគូ $\wedge$ $y+z$ ជាចំនួនគូ

$x+y$ ជាចំនួនគូ $\Rightarrow$ ( $x$ ជាចំនួនគូ និង $y$ ជាចំនួនគូ ) ឬ ( $x$ ជាចំនួនសេស និង $y$ ជាចំនួនសេស )

+ ករណី ( $x$ ជាចំនួនគូ និង $y$ ជាចំនួនគូ )

$\Rightarrow z$ ជាចំនួនគូ ( ព្រោះ $y+z$ ជាចំនួនគូ )

$\Rightarrow x+z$ ជាចំនួនគូ

$\Leftrightarrow\ x\mathcal{R}\,z$

+ ករណី ( $x$ ជាចំនួនសេស និង $y$ ជាចំនួនសេស )

$\Rightarrow z$ ជាចំនួនសេស ( ព្រោះ $y+z$ ជាចំនួនគូ )

$\Rightarrow x+z$ ជាចំនួនគូ

$\Leftrightarrow\ x\mathcal{R}\,z$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះស្មើទេ

10. គេឱ្យអនុគមន៍ប្រកាន់ $f:\mathbb{R}\to\mathbb{R}$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}$ កំណត់ដោយ :

$x\mathcal{R}\,x' \Leftrightarrow f(x)\le f(x')$ ។ ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x\in\mathbb{R}:\ f(x)\le f(x)\Leftrightarrow\ x\mathcal{R}\,x$

លក្ខណៈឆ្លុះ $\forall x, y \in \mathbb{R}: \ x \mathcal{R} y \Leftrightarrow f(x) \leq f(y)$

$\nRightarrow f(y) \leq f(x)$

$\nRightarrow y \mathcal{R} x$

លក្ខណៈឆ្លុះស្មើ $\forall x, y \in \mathbb{R}: \ x \mathcal{R} y \wedge y \mathcal{R} x$

$$\Leftrightarrow \begin{cases} f(x) \leq f(y) \\ f(y) \leq f(x) \end{cases}$$

$\Rightarrow f(x) = f(y)$

ដោយគេមានអនុគមន៍ប្រកាន់ $f: \mathbb{R} \to \mathbb{R}$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}$

$\Rightarrow x = y$

លក្ខណៈឆ្លង $\forall x, y, z \in \mathbb{R}: \ x \mathcal{R} y \wedge y \mathcal{R} z$

$$\Leftrightarrow \begin{cases} f(x) \leq f(y) \\ f(y) \leq f(z) \end{cases}$$

$\Rightarrow f(x) \leq f(z)$

$\Rightarrow x \mathcal{R} z$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះស្មើ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះ ទេ

11. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}$ កំណត់ដោយ $a \mathcal{R} b \Leftrightarrow a \leq b$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x \in \mathbb{R} \ : \ x \leq x \Leftrightarrow x \mathcal{R} x$

លក្ខណៈឆ្លុះ $\forall x, y \in \mathbb{R} \ : \ x \mathcal{R} y \Leftrightarrow x \le y$

$\nRightarrow y \le x$

$\nRightarrow y \mathcal{R} x$

លក្ខណៈឆ្លុះស្មើ $\forall x, y \in \mathbb{R} \ : \ x \mathcal{R} y \wedge y \mathcal{R} x$

$$\Leftrightarrow \begin{cases} x \le y \\ y \le x \end{cases}$$

$\Leftrightarrow x = y$

លក្ខណៈឆ្លង $\forall x, y, z \in \mathbb{R} \ : \ x \mathcal{R} y \wedge y \mathcal{R} z$

$$\Leftrightarrow \begin{cases} x \le y \\ y \le z \end{cases}$$

$\Rightarrow x \le z$

$\Leftrightarrow x \mathcal{R} z$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះស្មើ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះ ទេ

12. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}^*$ កំណត់ដោយ $a \mathcal{R} b \Leftrightarrow a | b$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x \in \mathbb{N}^* \ : \ x | x \Leftrightarrow x \mathcal{R} x$

លក្ខណៈឆ្លុះ $\forall x, y \in \mathbb{N}^* \ : \ x \mathcal{R} y \Leftrightarrow x | y$

$\nRightarrow y | x$

$\nRightarrow y \mathcal{R} x$

លក្ខណៈឆ្លុះស្មើ $\forall x,y\in\mathbb{N}^* \ : \ x\mathcal{R}y \wedge y\mathcal{R}x$

$$\Leftrightarrow \begin{cases} x|y \\ y|x \end{cases}$$

$$\Leftrightarrow x=y$$

លក្ខណៈឆ្លង $\forall x,y,z\in\mathbb{N}^* \ : \ x\mathcal{R}y \wedge y\mathcal{R}z$

$$\Leftrightarrow \begin{cases} x|y \\ y|z \end{cases}$$

$$\Rightarrow x|z$$

$$\Leftrightarrow x\mathcal{R}z$$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះស្មើ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះ ទេ

13. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}\times\mathbb{R}$ កំណត់ដោយ $(a,b)\mathcal{R}(c,d)\Leftrightarrow a\le c\wedge b\le d$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall(x_1,x_2)\in\mathbb{R}\times\mathbb{R} \ : \ x_1\le x_1\wedge x_2\le x_2 \Leftrightarrow (x_1,x_2)\mathcal{R}(x_1,x_2)$

លក្ខណៈឆ្លុះ $\forall(x_1,x_2),(y_1,y_2)\in\mathbb{R}\times\mathbb{R} \ : \ (x_1,x_2)\mathcal{R}(y_1,y_2) \Leftrightarrow x_1\le y_1\wedge x_2\le y_2$

$$\not\Rightarrow y_1\le x_1\wedge y_2\le x_2$$

$$\not\Rightarrow (y_1,y_2)\mathcal{R}(x_1,x_2)$$

លក្ខណៈឆ្លុះស្មើ $\forall(x_1,x_2),(y_1,y_2)\in\mathbb{R}\times\mathbb{R} \ : \ (x_1,x_2)\mathcal{R}(y_1,y_2) \wedge (y_1,y_2)\mathcal{R}(x_1,x_2)$

$$\Leftrightarrow \begin{cases} x_1\le y_1\wedge x_2\le y_2 \\ y_1\le x_1\wedge y_2\le x_2 \end{cases}$$

$$\Leftrightarrow \begin{cases} x_1 \le y_1 \wedge y_1 \le x_1 \\ x_2 \le y_2 \wedge y_2 \le x_2 \end{cases}$$

$$\Rightarrow \begin{cases} x_1 = y_1 \\ x_2 = y_2 \end{cases}$$

លក្ខណៈឆ្លង $\forall (x_1,x_2),(y_1,y_2),(z_1,z_2) \in \mathbb{R}\times\mathbb{R}$ :

$$(x_1,x_2)\ \mathcal{R}\ (y_1,y_2) \wedge (y_1,y_2)\ \mathcal{R}\ (z_1,z_2)$$

$$\Leftrightarrow \begin{cases} x_1 \le y_1 \wedge x_2 \le y_2 \\ y_1 \le z_1 \wedge y_2 \le z_2 \end{cases}$$

$$\Leftrightarrow \begin{cases} x_1 \le y_1 \wedge y_1 \le z_1 \\ x_2 \le y_2 \wedge y_2 \le z_2 \end{cases}$$

$$\Rightarrow x_1 \le z_1 \wedge x_2 \le z_2$$

$$\Leftrightarrow (x_1,x_2)\ \mathcal{R}\ (z_1,z_2)$$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះស្មើ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះ ទេ

14. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}\times\mathbb{R}$ កំណត់ដោយ :

$$(a,b)\mathcal{R}(c,d) \Leftrightarrow [a<c \vee (a=c \wedge b \le d)]$$

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall (x_1,x_2) \in \mathbb{R}\times\mathbb{R}$ : $[x_1 < x_1 \vee (x_1 = x_1 \wedge x_2 \le x_2)]$

$$\Leftrightarrow (x_1,x_2)\ \mathcal{R}\ (x_1,x_2)$$

លក្ខណៈឆ្លុះ $\forall (x_1,x_2),(y_1,y_2) \in \mathbb{R}\times\mathbb{R}$ : $(x_1,x_2)\ \mathcal{R}\ (y_1,y_2)$

$$\Leftrightarrow [x_1 < y_1 \vee (x_1 = y_1 \wedge x_2 \le y_2)]$$

$$\not\Rightarrow [y_1 < x_1 \vee (y_1 = x_1 \wedge y_2 \le x_2)]$$

$\not\Rightarrow\ (y_1,y_2)\ \mathcal{R}\ (x_1,x_2)$

លក្ខណៈឆ្លុះស្មើ $\forall(x_1,x_2),(y_1,y_2)\in\mathbb{R}\times\mathbb{R}\ :\ (x_1,x_2)\ \mathcal{R}\ (y_1,y_2)\ \wedge\ (y_1,y_2)\ \mathcal{R}\ (x_1,x_2)$

$$\Leftrightarrow\begin{cases}[x_1<y_1\vee(x_1=y_1\wedge x_2\le y_2)]\\ [y_1<x_1\vee(y_1=x_1\wedge y_2\le x_2)]\end{cases}$$

លក្ខខណ្ឌនេះតម្រូវឱ្យ $x_1=y_1$ និង $x_2=y_2$

លក្ខណៈឆ្លង $\forall(x_1,x_2),(y_1,y_2),(z_1,z_2)\in\mathbb{R}\times\mathbb{R}\ :$

$(x_1,x_2)\ \mathcal{R}\ (y_1,y_2)\ \wedge\ (y_1,y_2)\ \mathcal{R}\ (z_1,z_2)$

$$\Leftrightarrow\begin{cases}[x_1<y_1\vee(x_1=y_1\wedge x_2\le y_2)]\\ [y_1<z_1\vee(y_1=z_1\wedge y_2\le z_2)]\end{cases}$$

$\Rightarrow\ x_1<z_1\ \vee\ (x_1=z_1\wedge x_2\le z_2)$

$\Leftrightarrow\ (x_1,x_2)\ \mathcal{R}\ (z_1,z_2)$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះស្មើ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះ ទេ

15. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x\,\mathcal{R}\,y\Leftrightarrow x+\dfrac{1}{x}=y+\dfrac{1}{y}$ ។

ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall x\in\mathbb{R}^*\ :\ x+\dfrac{1}{x}=x+\dfrac{1}{x}\ \Leftrightarrow\ x\,\mathcal{R}\,x$

លក្ខណៈឆ្លុះ $\forall x,y\in\mathbb{R}^*\ :\ x\,\mathcal{R}\,y\Leftrightarrow x+\dfrac{1}{x}=y+\dfrac{1}{y}$

$$\Leftrightarrow y+\frac{1}{y}=x+\frac{1}{x}$$

$$\Leftrightarrow y\,\mathcal{R}\,x$$

លក្ខណៈឆ្លុះស្មើ $\forall x,y\in\mathbb{R}^* \ : \ x\mathcal{R}\, y \ \wedge \ y\mathcal{R}\, x$

$$\Leftrightarrow \begin{cases} x+\dfrac{1}{x}=y+\dfrac{1}{y} \\ y+\dfrac{1}{y}=x+\dfrac{1}{x} \end{cases}$$

$$\Leftrightarrow \ x+\frac{1}{x}=y+\frac{1}{y}$$

$$\Leftrightarrow \ x-y=\frac{1}{y}-\frac{1}{x}$$

$$\Leftrightarrow \ x-y=\frac{x-y}{xy}$$

$$\Leftrightarrow \ x-y-\frac{x-y}{xy}=0$$

$$\Leftrightarrow \ (x-y)\left(1-\frac{1}{xy}\right)=0$$

$$\Rightarrow \left[\begin{array}{l} x-y=0 \\ 1-\dfrac{1}{xy}=0 \end{array}\right.$$

$$\Rightarrow \left[\begin{array}{l} x=y \\ 1=\dfrac{1}{xy} \end{array}\right.$$

$$\Rightarrow \left[\begin{array}{l} x=y \\ xy=1 \end{array}\right.$$

$$\Rightarrow \left[\begin{array}{l} x=y \\ x=\dfrac{1}{y} \end{array}\right.$$

$$\Rightarrow \ x=y$$

លក្ខណៈឆ្លង $\forall x,y,z \in \mathbb{R}^* \quad : \ x \mathcal{R} y \ \wedge \ y \mathcal{R} z$

$$\Leftrightarrow \begin{cases} x + \dfrac{1}{x} = y + \dfrac{1}{y} \\ y + \dfrac{1}{y} = z + \dfrac{1}{z} \end{cases}$$

$$\Leftrightarrow \ x + \frac{1}{x} = z + \frac{1}{z}$$

$$\Leftrightarrow \ x \mathcal{R} z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើសំណុំ $\mathbb{R}^*$

16. គេឱ្យ $A$ ជាសំណុំរងនៃសំណុំ $E$ ។ លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$X \mathcal{R} Y \Leftrightarrow A \cap X = A \cap Y$ ។ ចូរសិក្សាលក្ខណៈនៃទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ ។

លក្ខណៈខ្លួនឯង $\forall X \in \mathcal{P}(E) : \ A \cap X = A \cap X \ \Leftrightarrow X \mathcal{R} X$

លក្ខណៈឆ្លុះ $\forall X, Y \in \mathcal{P}(E) : \ X \mathcal{R} Y$

$\Leftrightarrow A \cap X = A \cap Y \ \Leftrightarrow A \cap Y = A \cap X \ \Leftrightarrow Y \mathcal{R} X$

លក្ខណៈឆ្លុះស្មើ $\forall X, Y \in \mathcal{P}(E) : \ X \mathcal{R} Y \ \wedge \ Y \mathcal{R} X$

$$\Leftrightarrow \begin{cases} A \cap X = A \cap Y \\ A \cap Y = A \cap X \end{cases} \Leftrightarrow A \cap X = A \cap Y \nRightarrow X = Y$$

លក្ខណៈឆ្លង $\forall X, Y, Z \in \mathcal{P}(E) : \ X \mathcal{R} Y \ \wedge \ Y \mathcal{R} Z$

$$\Leftrightarrow \begin{cases} A \cap X = A \cap Y \\ A \cap Y = A \cap Z \end{cases} \Leftrightarrow A \cap X = A \cap Z \Leftrightarrow X \mathcal{R} Z$$

$\therefore$ $\mathcal{R}$ មានលក្ខណៈខ្លួនឯង , លក្ខណៈឆ្លុះ , លក្ខណៈឆ្លង តែគ្មានលក្ខណៈឆ្លុះស្មើ ទេ

# ទំនាក់ទំនងសមមូល

## ផ្នែកប្រធានលំហាត់

1. គេឱ្យអនុគមន៍ $f:E\to F$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ កំណត់ដោយ :

   $x\,\mathcal{R}\,x' \Leftrightarrow f(x)=f(x')$ ។

   ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $E$ ។

   ខ. បើ $E=F=\mathbb{R}$ និង $f(x)=\sin x$ ។ ចូររកថ្នាក់សមមូលនៃធាតុ $a\in\mathbb{R}$ ។

2. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}\times\mathbb{N}$ កំណត់ដោយ $(a,b)\,\mathcal{R}\,(c,d)\Leftrightarrow a+d=b+c$ ។

   ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}\times\mathbb{N}$ ។

   ខ. ចូររកថ្នាក់សមមូលនៃធាតុ $(2,3)\in\mathbb{N}^2$ ។

3. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}\times\mathbb{Z}^*$ កំណត់ដោយ $(a,b)\,\mathcal{R}\,(c,d)\Leftrightarrow a.d=b.c$ ។

   តើ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{Z}\times\mathbb{Z}^*$ ឬទេ ?

4. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}$ កំណត់ដោយ $a\,\mathcal{R}\,b\Leftrightarrow a+b$ ជាចំនួនគូ ។

   ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}$ ។

   ខ.ចូររកថ្នាក់សមមូលនៃធាតុ $p\in\mathbb{N}$ ។

5. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x\,\mathcal{R}\,y\Leftrightarrow x+\dfrac{1}{x}=y+\dfrac{1}{y}$ ។

   ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$ ។

   ខ. ចូររកថ្នាក់សមមូលនៃធាតុ $a\in\mathbb{R}^*$ ។

6. លើ $\mathbb{R}$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x \mathcal{R} y \Leftrightarrow x^2 - y^2 = x - y$ ។

ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}$ ។

ខ. ចូររកថ្នាក់សមមូលនៃធាតុ $a \in \mathbb{R}$ ។

7. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x \mathcal{R} y \Leftrightarrow x^2 - \frac{1}{x^2} = y^2 - \frac{1}{y^2}$ ។

ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$ ។

ខ. ចូររកថ្នាក់សមមូលនៃធាតុ $a \in \mathbb{R}^*$ ។

8. គេឱ្យ $A$ ជាសំណុំរងនៃសំណុំ $E$ ។ លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$X \mathcal{R} Y \Leftrightarrow A \cap X = A \cap Y$ ។ បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$ ។

9. លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$\forall A, B \in \mathcal{P}(E) : A \mathcal{R} B \Leftrightarrow n(A \Delta B)$ ជាចំនួនគត់គូ ។

បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$ ។

10. គេឱ្យ $M_0$ ជាចំណុចមួយនៃប្លង់ $P$ ។ លើប្លង់ $P$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$\forall M, M' \in P : M \mathcal{R} M' \Leftrightarrow M_0 , M , M'$ រត់ត្រង់គ្នា ។

ក. តើ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $P$ ឬទេ ?

ខ. គេតាង $P^* = P - \{M_0\}$ ។ បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $P^*$ ។

រួចរកថ្នាក់សមមូលនៃចំណុច $M$ មួយរបស់ $P^*$ ។

11. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}^* \times \mathbb{R}^*$ កំណត់ដោយ :

$\forall (x, y), (x', y') \in \mathbb{R}^* \times \mathbb{R}^* : (x, y) \mathcal{R} (x', y') \Leftrightarrow \exists k \in \mathbb{R}^* : x' = k.x \wedge y' = k.y$ ។

ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^* \times \mathbb{R}^*$ ។

ខ. ចូររកថ្នាក់សមមូលនៃធាតុ $(1,2) \in \mathbb{R}^* \times \mathbb{R}^*$ ។

12. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ មានលក្ខណៈខ្លួនឯង និង លក្ខណៈឆ្លង ។

លើ $E$ គេកំណត់ទំនាក់ទំនង $\mathcal{T}$ មួយទៀតដោយ :

$\forall x, y \in E : x \mathcal{T} y \Leftrightarrow x \mathcal{R} y \ \wedge y \mathcal{R} x$ ។ បង្ហាញថា $\mathcal{T}$ ជាទំនាក់ទំនងសមមូលលើ $E$ ។

## ផ្នែកដំណោះស្រាយ

1. គេឱ្យអនុគមន៍ $f : E \to F$ និង $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ កំណត់ដោយ :

$x \mathcal{R} x' \Leftrightarrow f(x) = f(x')$ ។

ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $E$ ។

លក្ខណៈខ្លួនឯង : $\forall x \in E \quad : \quad f(x) = f(x) \Leftrightarrow \ x \mathcal{R} x$

លក្ខណៈឆ្លុះ : $\forall x, y \in E \quad : \quad x \mathcal{R} y$

$$\Leftrightarrow \ f(x) = f(y)$$
$$\Leftrightarrow \ f(y) = f(x)$$
$$\Leftrightarrow \ y \mathcal{R} x$$

លក្ខណៈឆ្លង : $\forall x, y, z \in E \quad : \quad x \mathcal{R} y \ \wedge \ y \mathcal{R} z$

$$\Leftrightarrow \begin{cases} f(x) = f(y) \\ f(y) = f(z) \end{cases} \Rightarrow \ f(x) = f(z) \ \Leftrightarrow \ x \mathcal{R} z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $E$

ខ. បើ $E=F=\mathbb{R}$ និង $f(x)=\sin x$ ។ ចូររកថ្នាក់សមមូលនៃធាតុ $a\in\mathbb{R}$ ។

ថ្នាក់សមមូលនៃធាតុ $a$ តាងដោយ $\bar{a}=\{\ x\in\mathbb{R}:\ a\,\mathcal{R}\,x\ \}$

$\Leftrightarrow\ \ \bar{a}=\{\ x\in\mathbb{R}:\ f(a)=f(x)\ \}$

$\Leftrightarrow\ \ \bar{a}=\{\ x\in\mathbb{R}:\ \sin a=\sin x\ \}$

$\Leftrightarrow\ \ \bar{a}=\{a+2k\pi\,,\pi-a+2k\pi\}$

$\therefore$ ថ្នាក់សមមូលនៃធាតុ $a$ គឺ $\bar{a}=\{a+2k\pi\,,\pi-a+2k\pi\}$

2. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}\times\mathbb{N}$ កំណត់ដោយ $(a,b)\,\mathcal{R}\,(c,d)\Leftrightarrow a+d=b+c$ ។

ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}\times\mathbb{N}$ ។

លក្ខណៈខ្លួនឯង : $\forall(x_1,x_2)\in\mathbb{N}\times\mathbb{N}\ :\ x_1+x_2=x_2+x_1\Leftrightarrow(x_1,x_2)\,\mathcal{R}\,(x_1,x_2)$

លក្ខណៈឆ្លុះ : $\forall(x_1,x_2),(y_1,y_2)\in\mathbb{N}\times\mathbb{N}\ :\ (x_1,x_2)\,\mathcal{R}\,(y_1,y_2)$

$$\Leftrightarrow\ x_1+y_2=x_2+y_1$$
$$\Leftrightarrow\ y_2+x_1=y_1+x_2$$
$$\Leftrightarrow\ y_1+x_2=y_2+x_1$$
$$\Leftrightarrow\ (y_1,y_2)\,\mathcal{R}\,(x_1,x_2)$$

លក្ខណៈឆ្លង : $\forall(x_1,x_2),(y_1,y_2),(z_1,z_2)\in\mathbb{N}\times\mathbb{N}\ :$

$(x_1,x_2)\,\mathcal{R}\,(y_1,y_2)\ \wedge\ (y_1,y_2)\,\mathcal{R}\,(z_1,z_2)$

$$\Leftrightarrow\begin{cases}x_1+y_2=x_2+y_1\\ y_1+z_2=y_2+z_1\end{cases}$$

$$\Leftrightarrow\begin{cases}x_1-x_2=y_1-y_2\\ y_1-y_2=z_1-z_2\end{cases}$$

$$\Rightarrow\ x_1-x_2=z_1-z_2$$

$$\Rightarrow\ x_1+z_2=x_2+z_1$$

$$\Leftrightarrow\ (x_1,x_2)\,\mathcal{R}\,(z_1,z_2)$$

$\therefore$ | $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}\times\mathbb{N}$

ខ. ចូររកថ្នាក់សមមូលនៃធាតុ $(2,3)\in\mathbb{N}^2$ ។

ថ្នាក់សមមូលនៃធាតុ $(2,3)$ តាងដោយ $\overline{(2,3)}=\{\ (x_1,x_2)\in\mathbb{N}^2\ :\ (2,3)\ \mathcal{R}\ (x_1,x_2)\ \ \}$

$\Leftrightarrow\ \ \overline{(2,3)}=\{\ (x_1,x_2)\in\mathbb{N}^2\ :\ 2+x_2=3+x_1\ \ \}$

$\Leftrightarrow\ \ \overline{(2,3)}=\{\ (x_1,x_2)\in\mathbb{N}^2\ :\ x_2=x_1+1\ \ \}$

$\Leftrightarrow\ \ \overline{(2,3)}=\{(0,1),(1,2),(2,3),(3,4),\ldots\ldots\}$

$\therefore$ | ថ្នាក់សមមូលនៃធាតុ $(2,3)$ គឺ $\overline{(2,3)}=\{(0,1),(1,2),(2,3),(3,4),\ldots\ldots\}$

3. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{Z}\times\mathbb{Z}^*$ កំណត់ដោយ $(a,b)\,\mathcal{R}\,(c,d)\Leftrightarrow a.d=b.c$ ។

តើ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{Z}\times\mathbb{Z}^*$ ឬទេ ?

លក្ខណៈខ្លួនឯង : $\forall(x_1,x_2)\in\mathbb{Z}\times\mathbb{Z}^*\ :\ x_1.x_2=x_2.x_1\Leftrightarrow (x_1,x_2)\,\mathcal{R}\,(x_1,x_2)$

លក្ខណៈឆ្លុះ : $\forall(x_1,x_2),(y_1,y_2)\in\mathbb{Z}\times\mathbb{Z}^*\ :\ (x_1,x_2)\ \mathcal{R}\ (y_1,y_2)$

$$\Leftrightarrow\ x_1.y_2=x_2.y_1$$

$$\Leftrightarrow\ y_2.x_1=y_1.x_2$$

$$\Leftrightarrow\ y_1.x_2=y_2.x_1$$

$$\Leftrightarrow\ (y_1,y_2)\ \mathcal{R}\ (x_1,x_2)$$

លក្ខណៈឆ្លង : $\forall(x_1,x_2),(y_1,y_2),(z_1,z_2)\in\mathbb{Z}\times\mathbb{Z}^*\ :$

$(x_1,x_2)\ \mathcal{R}\ (y_1,y_2)\ \wedge\ (y_1,y_2)\ \mathcal{R}\ (z_1,z_2)$

$$\Leftrightarrow\ \begin{cases}x_1.y_2=x_2.y_1\\ y_1.z_2=y_2.z_1\end{cases}$$

$$\Leftrightarrow \begin{cases} \dfrac{x_1}{x_2} = \dfrac{y_1}{y_2} \\ \dfrac{y_1}{y_2} = \dfrac{z_1}{z_2} \end{cases}$$

$$\Rightarrow \frac{x_1}{x_2} = \frac{z_1}{z_2}$$

$$\Rightarrow x_1.z_2 = x_2.z_1$$

$$\Leftrightarrow (x_1, x_2) \mathcal{R} (z_1, z_2)$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{Z} \times \mathbb{Z}^*$

4. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{N}$ កំណត់ដោយ $a \mathcal{R} b \Leftrightarrow a + b$ ជាចំនួនគូ ។

ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}$ ។

លក្ខណៈខ្លួនឯង : $\forall x \in \mathbb{N}$ : $x + x$ ជាចំនួនគូ ( ព្រោះ $x + x = 2x$ ជាចំនួនគូ )

$\Leftrightarrow x \mathcal{R} x$

លក្ខណៈឆ្លុះ : $\forall x, y \in \mathbb{N}$ : $x \mathcal{R} y$

$\Leftrightarrow x + y$ ជាចំនួនគូ

$\Leftrightarrow y + x$ ជាចំនួនគូ

$\Leftrightarrow y \mathcal{R} x$

លក្ខណៈឆ្លង : $\forall x, y, z \in \mathbb{N}$ : $x \mathcal{R} y \wedge y \mathcal{R} z$

$\Leftrightarrow x + y$ ជាចំនួនគូ និង $y + z$ ជាចំនួនគូ

$x + y$ ជាចំនួនគូ នោះគេបាន ( $x$ គូ និង $y$ គូ ) ឬ ( $x$ សេស និង $y$ សេស )

- $x$ គូ និង $y$ គូ

  $\Rightarrow$ $z$ គូ ( ព្រោះ $y+z$ ជាចំនួនគូ )

  $\Rightarrow$ $x+z$ ជាចំនួនគូ

  $\Leftrightarrow$ $x \mathcal{R} z$

- $x$ សេស និង $y$ សេស

  $\Rightarrow$ $z$ សេស ( ព្រោះ $y+z$ ជាចំនួនគូ )

  $\Rightarrow$ $x+z$ ជាចំនួនគូ

  $\Leftrightarrow$ $x \mathcal{R} z$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{N}$

ខ.ចូររកថ្នាក់សមមូលនៃធាតុ $p \in \mathbb{N}$ ។

ថ្នាក់សមមូលនៃធាតុ $p$ តាងដោយ $\overline{p} = \{ x \in \mathbb{N} : p \mathcal{R} x \}$

$\Leftrightarrow$ $\overline{p} = \{ x \in \mathbb{N} : p + x$ ជាចំនួនគូ $\}$

$\Leftrightarrow$ $\overline{p} = \{ x \in \mathbb{N} : p + x = 2k \}$

$\Leftrightarrow$ $\overline{p} = \{ x \in \mathbb{N} : x = 2k - p \}$

$\therefore$ ថ្នាក់សមមូលនៃធាតុ $p$ គឺ $\overline{p} = \{ 2k - p \, , \, k, p \in \mathbb{N} \}$

5. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x \mathcal{R} y \Leftrightarrow x + \dfrac{1}{x} = y + \dfrac{1}{y}$ ។

ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$ ។

លក្ខណៈខ្លួនឯង : $\forall x \in \mathbb{R}^* \;:\; x + \frac{1}{x} = x + \frac{1}{x}$

$$\Leftrightarrow \; x \mathcal{R} x$$

លក្ខណៈឆ្លុះ : $\forall x, y \in \mathbb{R}^* \;:\; x \mathcal{R} y$

$$\Leftrightarrow \; x + \frac{1}{x} = y + \frac{1}{y}$$

$$\Leftrightarrow \; y + \frac{1}{y} = x + \frac{1}{x}$$

$$\Leftrightarrow \; y \mathcal{R} x$$

លក្ខណៈឆ្លង : $\forall x, y, z \in \mathbb{R}^* \;:\; x \mathcal{R} y \wedge y \mathcal{R} z$

$\Leftrightarrow \; x + \frac{1}{x} = y + \frac{1}{y}$ និង $y + \frac{1}{y} = z + \frac{1}{z}$

$$\Rightarrow \; x + \frac{1}{x} = z + \frac{1}{z}$$

$$\Leftrightarrow \; x \mathcal{R} z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$

ខ. ចូររកថ្នាក់សមមូលនៃធាតុ $a \in \mathbb{R}^*$ ។

ថ្នាក់សមមូលនៃធាតុ $a$ តាងដោយ $\bar{a} = \{ \; x \in \mathbb{R}^* \;:\; a \mathcal{R} x \; \}$

$$\Leftrightarrow \; \bar{a} = \left\{ \; x \in \mathbb{R}^* \;:\; a + \frac{1}{a} = x + \frac{1}{x} \; \right\}$$

$$\Leftrightarrow \; \bar{a} = \left\{ \; x \in \mathbb{R}^* \;:\; a - x = \frac{1}{x} - \frac{1}{a} \; \right\}$$

$$\Leftrightarrow \; \bar{a} = \left\{ \; x \in \mathbb{R}^* \;:\; a - x = \frac{a - x}{ax} \; \right\}$$

$$\Leftrightarrow \; \bar{a} = \left\{ \; x \in \mathbb{R}^* \;:\; a - x - \frac{a - x}{ax} = 0 \; \right\}$$

$$\Leftrightarrow \quad \bar{a} = \left\{ \ x \in \mathbb{R}^* : \ (a-x)\left(1-\frac{1}{ax}\right) = 0 \ \right\}$$

$$\Leftrightarrow \quad \bar{a} = \left\{ \ x \in \mathbb{R}^* : \ x = a \ , \ x = \frac{1}{a} \ \right\}$$

$$\Leftrightarrow \quad \bar{a} = \left\{ a \ , \frac{1}{a} \right\}$$

$\therefore$ ថ្នាក់សមមូលនៃធាតុ $a$ គឺ $\bar{a} = \left\{ a \ , \frac{1}{a} \right\}$

6. លើ $\mathbb{R}$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x \mathcal{R} y \Leftrightarrow x^2 - y^2 = x - y$ ។

ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}$ ។

លក្ខណៈខ្លួនឯង : $\forall x \in \mathbb{R} \ : \quad x^2 - x^2 = x - x$

$$\Leftrightarrow \quad x \mathcal{R} x$$

លក្ខណៈឆ្លុះ : $\forall x, y \in \mathbb{R} \ : \quad x \mathcal{R} y$

$$\Leftrightarrow \quad x^2 - y^2 = x - y \quad \Rightarrow \quad -\left(x^2 - y^2\right) = -(x-y)$$

$$\Rightarrow \quad y^2 - x^2 = y - x$$

$$\Leftrightarrow \quad y \mathcal{R} x$$

លក្ខណៈឆ្លង : $\forall x, y, z \in \mathbb{R} \quad : \quad x \mathcal{R} y \ \wedge \ y \mathcal{R} z$

$$\Leftrightarrow \quad x^2 - y^2 = x - y \ \text{ និង } \ y^2 - z^2 = y - z$$

$$\Leftrightarrow \quad x^2 - x = y^2 - y \ \text{ និង } \ y^2 - y = z^2 - z$$

$$\Rightarrow \quad x^2 - x = z^2 - z$$

$$\Leftrightarrow \quad x^2 - z^2 = x - z$$

$$\Leftrightarrow \quad x \mathcal{R} z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}$

ខ. ចូររកថ្នាក់សមមូលនៃធាតុ $a \in \mathbb{R}$ ។

ថ្នាក់សមមូលនៃធាតុ $a$ តាងដោយ $\bar{a} = \{ \ x \in \mathbb{R} : \ a \mathcal{R} x \ \}$

$\Leftrightarrow \ \bar{a} = \{ \ x \in \mathbb{R} : \ a^2 - x^2 = a - x \ \}$

$\Leftrightarrow \ \bar{a} = \{ \ x \in \mathbb{R} : \ a^2 - x^2 - (a - x) = 0 \ \}$

$\Leftrightarrow \ \bar{a} = \{ \ x \in \mathbb{R} : \ (a - x)(a + x) - (a - x) = 0 \ \}$

$\Leftrightarrow \ \bar{a} = \{ \ x \in \mathbb{R} : \ (a - x)(a + x - 1) = 0 \ \}$

$\Leftrightarrow \ \bar{a} = \{ \ x \in \mathbb{R} : \ x = a \ , \ x = 1 - a \ \}$

$\Leftrightarrow \ \bar{a} = \{ a \ , 1 - a \}$

$\therefore$ ថ្នាក់សមមូលនៃធាតុ $a$ គឺ $\bar{a} = \{ a \ , 1 - a \}$

7. លើ $\mathbb{R}^*$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ $x \mathcal{R} y \Leftrightarrow x^2 - \dfrac{1}{x^2} = y^2 - \dfrac{1}{y^2}$ ។

ក. ចូរបង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$ ។

លក្ខណៈខ្លួនឯង : $\forall x \in \mathbb{R}^* \ : \ x^2 - \dfrac{1}{x^2} = x^2 - \dfrac{1}{x^2}$

$\Leftrightarrow \ x \mathcal{R} x$

លក្ខណៈឆ្លុះ : $\forall x, y \in \mathbb{R}^* \ : \ x \mathcal{R} y$

$$\Leftrightarrow \ x^2 - \frac{1}{x^2} = y^2 - \frac{1}{y^2}$$

$$\Leftrightarrow \quad y^2-\frac{1}{y^2}=x^2-\frac{1}{x^2}$$

$$\Leftrightarrow \quad y\,\mathcal{R}\,x$$

លក្ខណៈឆ្លង : $\forall x,y,z\in\mathbb{R}^*$ : $x\,\mathcal{R}\,y \wedge y\,\mathcal{R}\,z$

$$\Leftrightarrow \quad x^2-\frac{1}{x^2}=y^2-\frac{1}{y^2} \text{ និង } y^2-\frac{1}{y^2}=z^2-\frac{1}{z^2}$$

$$\Rightarrow \quad x^2-\frac{1}{x^2}=z^2-\frac{1}{z^2}$$

$$\Leftrightarrow \quad x\,\mathcal{R}\,z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^*$

ខ. ចូររកថ្នាក់សមមូលនៃធាតុ $a\in\mathbb{R}^*$ ។

ថ្នាក់សមមូលនៃធាតុ $a$ តាងដោយ $\bar{a}=\{\ x\in\mathbb{R} : a\,\mathcal{R}\,x\ \}$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : a^2-\frac{1}{a^2}=x^2-\frac{1}{x^2}\ \right\}$$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : a^2-x^2=\frac{1}{a^2}-\frac{1}{x^2}\ \right\}$$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : a^2-x^2=\frac{x^2-a^2}{(ax)^2}\ \right\}$$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : a^2-x^2-\frac{x^2-a^2}{(ax)^2}=0\ \right\}$$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : a^2-x^2+\frac{a^2-x^2}{(ax)^2}=0\ \right\}$$

$$\Leftrightarrow \quad \bar{a}=\left\{\ x\in\mathbb{R}^* : \left(a^2-x^2\right)\left(1+\frac{1}{(ax)^2}\right)=0\ \right\}$$

$$\Leftrightarrow \quad \bar{a} = \left\{ \ x \in \mathbb{R}^* : \ (a-x)(a+x)\left(1+\frac{1}{(ax)^2}\right)=0 \ \right\}$$

ដោយ $1+\dfrac{1}{(ax)^2} > 0$

$$\Leftrightarrow \quad \bar{a} = \left\{ \ x \in \mathbb{R}^* : \ x = a \ , x = -a \ \right\}$$

$$\Leftrightarrow \quad \bar{a} = \{a \ , -a\}$$

$\therefore$ ថ្នាក់សមមូលនៃធាតុ $a$ គឺ $\bar{a} = \{a \ , -a\}$

8. គេឱ្យ $A$ ជាសំណុំរងនៃសំណុំ $E$ ។ លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$X \mathcal{R} Y \Leftrightarrow A \cap X = A \cap Y$ ។ បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$ ។

លក្ខណៈខ្លួនឯង $\forall X \in \mathcal{P}(E) : \ A \cap X = A \cap X \ \Leftrightarrow X \mathcal{R} X$

លក្ខណៈឆ្លុះ $\forall X, Y \in \mathcal{P}(E) : \ X \mathcal{R} Y$

$\Leftrightarrow A \cap X = A \cap Y \ \Leftrightarrow A \cap Y = A \cap X \ \Leftrightarrow Y \mathcal{R} X$

លក្ខណៈឆ្លង $\forall X, Y, Z \in \mathcal{P}(E) : \ X \mathcal{R} Y \wedge Y \mathcal{R} Z$

$$\Leftrightarrow \begin{cases} A \cap X = A \cap Y \\ A \cap Y = A \cap Z \end{cases} \Leftrightarrow A \cap X = A \cap Z \Leftrightarrow X \mathcal{R} Z$$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$

9. លើ $\mathcal{P}(E)$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$\forall A, B \in \mathcal{P}(E) : A \mathcal{R} B \Leftrightarrow n(A \Delta B)$ ជាចំនួនគត់គូ ។

បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$ ។

លក្ខណៈខ្លួនឯង : $\forall A \in \mathcal{P}(E)$ : $n(A\Delta A) = n(\varnothing) = 0$ ជាចំនួនគត់គូ

( ព្រោះ $A\Delta A = \varnothing$ )

$\Leftrightarrow A \mathcal{R} A$

លក្ខណៈឆ្លុះ : $\forall A, B \in \mathcal{P}(E)$ : $A \mathcal{R} B$

$\Leftrightarrow n(A\Delta B)$ ជាចំនួនគត់គូ

$\Leftrightarrow n(B\Delta A)$ ជាចំនួនគត់គូ

( ព្រោះ $A\Delta B = B\Delta A$ )

$\Leftrightarrow B \mathcal{R} A$

លក្ខណៈឆ្លង : $\forall A, B, C \in \mathcal{P}(E)$ : $A \mathcal{R} B \wedge B \mathcal{R} C$

$\Leftrightarrow n(A\Delta B)$ ជាចំនួនគត់គូ និង $n(B\Delta C)$ ជាចំនួនគត់គូ

$n(A\Delta B) = n(A) + n(B) - 2n(A \cap B)$ ជាចំនួនគត់គូ

$\Rightarrow n(A) + n(B)$ ជាចំនួនគត់គូ

$n(B\Delta C) = n(B) + n(C) - 2n(B \cap C)$ ជាចំនួនគត់គូ

$\Rightarrow n(B) + n(C)$ ជាចំនួនគត់គូ

$\Rightarrow [n(A) + n(B)] + [n(B) + n(C)] = n(A) + n(C) + 2n(B)$ ជាចំនួនគត់គូ

$\Rightarrow n(A) + n(C)$ ជាចំនួនគត់គូ

$\Rightarrow n(A) + n(C) - 2n(A \cap C) = n(A\Delta C)$ ជាចំនួនគត់គូ

$\Leftrightarrow A \mathcal{R} C$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathcal{P}(E)$

10. គេឱ្យ $M_0$ ជាចំណុចមួយនៃប្លង់ $P$ ។ លើប្លង់ $P$ គេកំណត់ទំនាក់ទំនងទ្វេធាតុ $\mathcal{R}$ មួយដោយ :

$\forall M, M' \in P : M \mathcal{R} M' \Leftrightarrow M_0, M, M'$ រត់ត្រង់គ្នា ។

ក. តើ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $P$ ឬទេ ?

លក្ខណៈខ្លួនឯង :

ចំពោះគ្រប់ចំណុច $M$ នៃប្លង់ $P$ គេបាន : ចំណុច $M_0\,, M\,, M'$ រត់ត្រង់គ្នាជានិច្ច

( ព្រោះចំណុចទាំងបីនេះនៅលើបន្ទាត់តែមួយ ) ។

$\Leftrightarrow \quad M \mathcal{R} M$




លក្ខណៈឆ្លុះ : $M \mathcal{R} M'$ នោះគេបាន $M_0\,, M\,, M'$ រត់ត្រង់គ្នា

$\Rightarrow M_0\,, M'\,, M$ រត់ត្រង់គ្នា

$\Leftrightarrow \quad M' \mathcal{R} M$

លក្ខណៈឆ្លង : $\mathcal{R}$ គ្មានលក្ខណៈឆ្លងទេ

( ព្រោះជាទូទៅ $M \mathcal{R} M'$ និង $M' \mathcal{R} M''$ មិននាំឱ្យ $M \mathcal{R} M''$ ទេ )

ឧទាហរណ៍ : បើគេយក $M \neq M''$ ហើយ $M' = M_0$ និង $M_0 \notin (MM'')$ នោះគេបាន :

$M \mathcal{R} M'$ និង $M' \mathcal{R} M''$ តែ $M \mathcal{R} M''$ មិនពិតទេ

តែនៅក្នុង $P^* = P - \{M_0\}$ នោះទើប $\mathcal{R}$ មានលក្ខណៈឆ្លង

( ព្រោះក្នុងករណីនេះ $M \mathcal{R} M'$ និង $M' \mathcal{R} M''$ នាំឱ្យ $M \mathcal{R} M''$ ) ។

$\therefore$ $\mathcal{R}$ មិនមែនជាទំនាក់ទំនងសមមូលលើ $P$ ទេ

ខ. គេតាង $P^* = P - \{M_0\}$ ។ បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $P^*$ ។

តាមសម្រាយបញ្ជាក់ខាងលើយើងឃើញថានៅក្នុង $P^*$ ទំនាក់ទំនង $\mathcal{R}$ មានលក្ខណៈខ្លួនឯង លក្ខណៈឆ្លុះ និង លក្ខណៈឆ្លង ។

$\therefore$ $\boxed{\mathcal{R} \text{ ជាទំនាក់ទំនងសមមូលលើ } P^*}$

- $cl(M) = \left\{ M' \in P^* \mid M \,\mathcal{R}\, M' \right\}$ = សំណុំនៃចំណុច $M'$ ទាំងឡាយដែលរត់ត្រង់គ្នាជាមួយ $M_0$ និង $M$

$\therefore$ $\boxed{cl(M) = \text{ បន្ទាត់ } (M_0M) \text{ ដែលគ្មានចំណុច } M_0}$

11. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $\mathbb{R}^* \times \mathbb{R}^*$ កំណត់ដោយ :

$\forall (x, y), (x', y') \in \mathbb{R}^* \times \mathbb{R}^* : (x, y) \,\mathcal{R}\, (x', y') \Leftrightarrow \exists k \in \mathbb{R}^* : x' = k.x \wedge y' = k.y$ ។

ក. បង្ហាញថា $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^* \times \mathbb{R}^*$ ។

លក្ខណៈខ្លួនឯង : $\forall (x_1, x_2) \in \mathbb{R}^* \times \mathbb{R}^* \;:\; \exists k = 1 \in \mathbb{R}^* : x_1 = 1.x_1 \wedge x_2 = 1.x_2$

$\Leftrightarrow (x_1, x_2) \,\mathcal{R}\, (x_1, x_2)$

លក្ខណៈឆ្លុះ : $\forall (x_1, x_2), (y_1, y_2) \in \mathbb{R}^* \times \mathbb{R}^* \;:\; (x_1, x_2) \,\mathcal{R}\, (y_1, y_2)$

$\exists k \in \mathbb{R}^* : y_1 = k.x_1 \wedge y_2 = k.x_2$

$\Rightarrow \exists k' = \frac{1}{k} \in \mathbb{R}^* : x_1 = \frac{1}{k}.y_1 = k'.y_1 \wedge x_2 = \frac{1}{k}.y_2 = k'.y_2$

$\Leftrightarrow (y_1, y_2) \,\mathcal{R}\, (x_1, x_2)$

លក្ខណៈឆ្លង : $\forall (x_1, x_2), (y_1, y_2), (z_1, z_2) \in \mathbb{R}^* \times \mathbb{R}^* \;:$

$(x_1, x_2) \,\mathcal{R}\, (y_1, y_2) \wedge (y_1, y_2) \,\mathcal{R}\, (z_1, z_2)$

$\Leftrightarrow\ \exists k_1 \in \mathbb{R}^* : y_1 = k_1.x_1 \wedge y_2 = k_1.x_2$ និង $\exists k_2 \in \mathbb{R}^* : z_1 = k_2.y_1 \wedge z_2 = k_2.y_2$

$\Rightarrow \exists\, k' = k_1.k_2 \in \mathbb{R}^* : z_1 = (k_1.k_2).x_1 = k'.x_1 \wedge z_2 = (k_1.k_2).x_2 = k'.x_2$

$\Leftrightarrow\ (x_1, x_2)\ \mathcal{R}\ (z_1, z_2)$

$\therefore$ $\mathcal{R}$ ជាទំនាក់ទំនងសមមូលលើ $\mathbb{R}^* \times \mathbb{R}^*$

ខ. ចូររកថ្នាក់សមមូលនៃធាតុ $(1,2) \in \mathbb{R}^* \times \mathbb{R}^*$ ។

ថ្នាក់សមមូលនៃធាតុ $(1,2)$ តាងដោយ $cl[(1,2)] = \{\ (x_1, x_2) \in \mathbb{R}^* \times \mathbb{R}^* : (1,2)\,\mathcal{R}\,(x_1, x_2)\ \}$

$\Leftrightarrow\ cl[(1,2)] = \{\ (x_1, x_2) \in \mathbb{R}^* \times \mathbb{R}^* : \exists k \in \mathbb{R}^* : x_1 = k \wedge x_2 = 2k\ \}$

$\Leftrightarrow\ cl[(1,2)] = \{\ (x_1, x_2) \in \mathbb{R}^* \times \mathbb{R}^* : \exists k \in \mathbb{R}^* : x_2 = 2x_1\ \}$

ដូច្នេះ $(x_1, x_2) \in \mathbb{R}^* \times \mathbb{R}^*$ ដែលសមមូលនឹង $(1,2)$ តាម $\mathcal{R}$ មានលក្ខណៈ $x_2 = 2x_1$

$\therefore$ $(x_1, x_2)$ ជាធាតុនៃបន្ទាត់ $D$ ដែលមានសមីការ $x_2 = 2x_1$ ក្រៅពីចំណុច $(0,0)$



12. គេឱ្យ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ មានលក្ខណ:ខ្លួនឯង និង លក្ខណ:ឆ្លង ។

លើ $E$ គេកំណត់ទំនាក់ទំនង $\mathcal{T}$ មួយទៀតដោយ :

$\forall x,y \in E:\ x\,\mathcal{T}\,y \Leftrightarrow x\,\mathcal{R}\,y \wedge y\,\mathcal{R}\,x$ ។ បង្ហាញថា $\mathcal{T}$ ជាទំនាក់ទំនងសមមូលលើ $E$ ។

លក្ខណ:ខ្លួនឯង : $\forall x \in E \ :\ x\,\mathcal{R}\,x \wedge x\,\mathcal{R}\,x$

$\Leftrightarrow\ x\,\mathcal{T}\,x$

ព្រោះ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ មានលក្ខណ:ខ្លួនឯង $\forall x \in E:\ x\,\mathcal{R}\,x$

លក្ខណ:ឆ្លុះ : $\forall x,y \in E \ :\ x\,\mathcal{T}\,y$

$\Leftrightarrow\ x\,\mathcal{R}\,y \wedge y\,\mathcal{R}\,x$

$\Leftrightarrow\ y\,\mathcal{R}\,x \wedge x\,\mathcal{R}\,y$

$\Leftrightarrow\ y\,\mathcal{T}\,x$

លក្ខណ:ឆ្លង : $\forall x,y,z \in E \ :\ x\,\mathcal{T}\,y \wedge y\,\mathcal{T}\,z$

$\Leftrightarrow\ x\,\mathcal{R}\,y \wedge y\,\mathcal{R}\,x$ និង $y\,\mathcal{R}\,z \wedge z\,\mathcal{R}\,y$

$\Leftrightarrow\ x\,\mathcal{R}\,y \wedge y\,\mathcal{R}\,z$ និង $z\,\mathcal{R}\,y \wedge y\,\mathcal{R}\,x$

ដោយ $\mathcal{R}$ ជាទំនាក់ទំនងទ្វេធាតុលើ $E$ មានលក្ខណ:ឆ្លង

$\Rightarrow\ x\,\mathcal{R}\,z \wedge z\,\mathcal{R}\,x$

$\Leftrightarrow\ x\,\mathcal{R}\,z$

$\therefore$ | $\mathcal{T}$ ជាទំនាក់ទំនងសមមូលលើ $E$ |

# ប្រមាណវិធី

## ផ្នែកប្រធានលំហាត់

1. លើ $\mathbb{N}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ $\forall x, y \in \mathbb{N} : x * y = x + 3y$

   ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{N}$ ឬទេ ?

   ខ. តើ $\mathbb{N}$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

   គ. តើធាតុណាខ្លះនៃ $\mathbb{N}$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

2. លើ $\mathbb{Q}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ $\forall a, b \in \mathbb{Q} : a * b = a + b - a.b$

   ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{Q}$ ឬទេ ?

   ខ. តើ $\mathbb{Q}$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

   គ. តើធាតុណាខ្លះនៃ $\mathbb{Q}$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

3. លើ $\mathbb{Z}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ $\forall x, y \in \mathbb{Z} : x * y = 2x - 5y$

   ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{Z}$ ឬទេ ?

   ខ. តើ $\mathbb{Z}$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

   គ. តើធាតុណាខ្លះនៃ $\mathbb{Z}$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

4. លើ $\mathbb{Q}^*$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ $\forall a, b \in \mathbb{Q}^* : a * b = a + \frac{1}{b}$

   ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{Q}^*$ ឬទេ ?

   ខ. តើ $\mathbb{Q}^*$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

   គ. តើធាតុណាខ្លះនៃ $\mathbb{Q}^*$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

5. លើ $\mathbb{R}^2$ គេកំណត់ប្រមាណវិធីក្នុង $*$ ដោយ :

$$\forall (a,b),(a',b')\in\mathbb{R}^2 : (a,b)*(a',b')=(a.a'-b.b',ab'+a'b)$$

ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{R}^2$ ឬទេ ?

ខ. តើ $\mathbb{R}^2$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

គ. តើធាតុណាខ្លះនៃ $\mathbb{R}^2$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

ឃ. តាង $E=\{\ (a,0) : a\in\mathbb{R}\ \}$ ។

i. បង្ហាញថា $E$ ជាផ្នែកស្ថាបនៃ $\mathbb{R}^2$ ចំពោះប្រមាណវិធី $*$ ។

ii. បង្ហាញថាអនុវត្តន៍ $f:(E,*)\to(\ \mathbb{R}\ ,\ \bullet\ )$ ជា Isomorphisme ។

$$(a,0)\mapsto f(a,0)=a$$

6. លើ $\mathbb{Q}^2$ គេកំណត់ប្រមាណវិធីក្នុង $*$ ដោយ :

$$\forall (a,b),(a',b')\in\mathbb{Q}^2 : (a,b)*(a',b')=(a.a',a'b+b')$$

ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{Q}^2$ ឬទេ ?

ខ. តើ $\mathbb{Q}^2$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

គ. តើធាតុណាខ្លះនៃ $\mathbb{Q}^2$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

ឃ. តាង $E=\{\ (a,0) : a\in\mathbb{Q}\ \}$ ។

i. បង្ហាញថា $E$ ជាផ្នែកស្ថាបនៃ $\mathbb{Q}^2$ ចំពោះប្រមាណវិធី $*$ ។

ii. បង្ហាញថាអនុវត្តន៍ $f:(E,*)\to(\ \mathbb{Q}\ ,\ \bullet\ )$ ជា Isomorphisme ។

$$(a,0)\mapsto f(a,0)=a$$

7. លើ $\mathbb{Z}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ : $\forall x,y\in\mathbb{Z} : x*y=x+y+xy$

ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{Z}$ ឬទេ ?

ខ. តើ $\mathbb{Z}$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

គ. តើធាតុណាខ្លះនៃ $\mathbb{Z}$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

ឃ. តើប្រមាណវិធី $*$ មានលក្ខណៈបំបែកចំពោះប្រមាណវិធីបូក និង ប្រមាណវិធីគុណនៃ $\mathbb{Z}$ ឬទេ ?

8. លើ $\mathbb{R}^2$ គេកំណត់ប្រមាណវិធីក្នុង $*$ និង $\perp$ ដោយ :

$$\forall (a,b),(a',b')\in\mathbb{R}^2 \;:\; (a,b)*(a',b')=(a+a',b+b')$$

$$(a,b)\perp(a',b')=(a.a'-b.b',a.b'+a'b)$$

ក. តើប្រមាណវិធី $*$ , $\perp$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{R}^2$ ឬទេ ?

ខ. តើ $\mathbb{R}^2$ មានធាតុណឺតចំពោះប្រមាណវិធី $*$ , $\perp$ ឬទេ ?

គ. តើធាតុណាខ្លះនៃ $\mathbb{R}^2$ មានចម្រាសចំពោះប្រមាណវិធី $*$ , $\perp$ ?

ឃ. តើប្រមាណវិធី $\perp$ មានលក្ខណៈបំបែកចំពោះប្រមាណវិធី $*$ ឬទេ ?

ង. តាង $E=\{\ (a,0) : a\in\mathbb{R}\ \}$ ។

i. បង្ហាញថា $E$ ជាផ្នែកស្ថាបនៃ $\mathbb{R}^2$ ចំពោះប្រមាណវិធី $*$ និង $\perp$ ។

ii. បង្ហាញថាអនុវត្តន៍ $f:(E,*)\to(\ \mathbb{R}\ ,\ +\ )$ និង $f:(E,\perp)\to(\ \mathbb{R}\ ,\ \bullet\ )$ ជា Isomorphisme

$$(a,0)\mapsto f(a,0)=a \qquad\qquad (a,0)\mapsto f(a,0)=a$$

9. លើ $\mathbb{R}_+$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ : $\forall x,y\in\mathbb{R}_+ \;:\; x*y=\sqrt{x^2+y^2}$

ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{R}_+$ ឬទេ ?

ខ. តើ $\mathbb{R}_+$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

គ. តើធាតុណាខ្លះនៃ $\mathbb{R}_+$ មានចម្រាសចំពោះប្រមាណវិធី $*$ ?

ឃ. តើប្រមាណវិធីគុណនៃ $\mathbb{R}_+$ មានលក្ខណៈបំបែកចំពោះប្រមាណវិធី $*$ ឬទេ ?

ង. បង្ហាញថាអនុវត្តន៍ $f:(\ \mathbb{R}_+\ ,\ *\ )\to(\ \mathbb{R}_+\ ,\ +\ )$ ជា Isomorphisme ។

$$x\mapsto f(x)=x^2$$

ច. ចំពោះ $\forall x\in\mathbb{R}_+$ គណនា $\underbrace{x*x*\cdots\cdots*x}_{n\text{ តួ}}$ ។

10. លើ $\mathbb{R}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដោយ $\forall x,y\in\mathbb{R} \;:\; x*y=xy+(x^2-1)(y^2-1)$

ក. តើប្រមាណវិធី $*$ មានលក្ខណៈផ្តុំ , លក្ខណៈត្រឡប់លើ $\mathbb{R}$ ឬទេ ?

ខ. តើ $\mathbb{R}$ មានធាតុណឺតចំពោះប្រមាណវិធី $*$ ឬទេ ?

11. លើ $\mathbb{R}$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដែល $\forall a,b,c\in\mathbb{R}:\begin{cases}0*a=-a\\ a*(b*c)=c*(b*a)\end{cases}$

បង្ហាញថា $\forall a,b,c\in\mathbb{R}$ គេបាន $a*(b*c)=(a*b)*(-c)$ ។

12. គេឱ្យសំណុំ $E$ ប្រដាប់ដោយប្រមាណវិធីក្នុង $\bullet$ មានលក្ខណៈផ្តុំ ហើយ $x$, $y$ ជាពីរធាតុរបស់សំណុំ $E$ ដែល $x.y=y.x$ ។ បង្ហាញថា $\forall n,p\in\mathbb{N}^*$ គេបាន $x^n.y^p=y^p.x^n$ ។

13. គេឱ្យ $f:(E,*)\to(F,\perp)$ ជា Homomorphisme ។

ក. បង្ហាញថាបើ $A$ ជាផ្នែកស្ថាបនៃ $(E,*)$ នោះគេបាន $f(A)$ ជាផ្នែកស្ថាបនៃ $(F,\perp)$ ។

ខ. បង្ហាញថាបើ $B$ ជាផ្នែកស្ថាបនៃ $(F,\perp)$ នោះគេបាន $f^{-1}(B)$ ជាផ្នែកស្ថាបនៃ $(E,*)$ ។

14. គេឱ្យ $E$ ជាសំណុំមួយប្រដាប់ដោយប្រមាណវិធីក្នុង $*$ ។ លើ $\mathcal{P}(E)$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដែល :

$\forall A,B\in\mathcal{P}(E)\ :\ A*B=\{x*y:x\in A\wedge y\in B\}$ ។

ក. បង្ហាញថា $\forall A,A',B,B'\in\mathcal{P}(E)$ បើ $(A\subset A'\wedge B\subset B')\Rightarrow A*B\subset A'*B'$ ។

ខ. បង្ហាញថាបើប្រមាណវិធី $*$ មានលក្ខណៈផ្តុំលើ $E$ នោះប្រមាណវិធី $*$ មានលក្ខណៈផ្តុំលើ $\mathcal{P}(E)$ ។

គ. បង្ហាញថាបើប្រមាណវិធី $*$ មានលក្ខណៈត្រឡប់លើ $E$ នោះប្រមាណវិធី $*$ មានលក្ខណៈត្រឡប់លើ $\mathcal{P}(E)$

ឃ. បង្ហាញថាបើ $e$ ជាធាតុណឺតនៃ $(E,*)$ នោះគេបាន $\{e\}$ ជាធាតុណឺតនៃ $(\mathcal{P}(E),*)$ ។

15. គេឱ្យ $E$ ជាសំណុំមួយប្រដាប់ដោយប្រមាណវិធីក្នុង $*$ មានលក្ខណៈផ្តុំ ។ លើ $\mathcal{P}(E)$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដែល $\forall A,B\in\mathcal{P}(E)\ :\ A*B=\{x*y:x\in A\wedge y\in B\}$ ។

បង្ហាញថាចំពោះ $\forall a,b\in E$ គេបាន :

$\{a\}*E$ , $E*\{b\}$ , $\{a\}*E*\{b\}$ , $E*\{a\}*E$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ ។

16. គេឱ្យ $E$ ជាសំណុំមួយប្រដាប់ដោយប្រមាណវិធីក្នុង $*$ ។ លើ $\mathcal{P}(E)$ គេកំណត់ប្រមាណវិធីក្នុង $*$ មួយដែល $\forall A,B\in\mathcal{P}(E)\ :\ A*B=\{x*y:x\in A\wedge y\in B\}$ ។ ចំពោះ $\forall A,B,C\in\mathcal{P}(E)$ ចូរប្រៀបធៀប

ក. $A*(B\cap C)$ និង $(A*B)\cap(A*C)$

17. គេឱ្យ $E$ ជាសំណុំមួយប្រដាប់ដោយប្រមាណវិធីក្នុង $*$ មានលក្ខណៈផ្តុំ ។ លើ $\wp(E)$ គេកំណត់ប្រមាណវិធីក្នុង$*$ មួយដែល $\forall A,B\in\wp(E)$ : $A*B=\{x*y : x\in A\wedge y\in B\}$ ។

ក. បង្ហាញថា បើ $A$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ នោះគេបាន $A*A$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ ។

ខ. ចំពោះគ្រប់ផ្នែក $A$ នៃ $E$ គេតាង $A^c=\{x\in E : \forall a\in A , a*x=x*a\}$ ។

បង្ហាញថា $A^c$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ ។

18. គេឱ្យ $E$ ប្រដាប់ដោយប្រមាណវិធីក្នុង $*$ ។ តាង $A=\{x\in E : \forall(y,z)\in E , x*(y*z)=(x*y)*z\}$

ក. បង្ហាញថា $A$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ ។

ខ. បង្ហាញថាប្រមាណវិធី $*$ មានលក្ខណៈផ្តុំលើ $A$ ។

19. គេឱ្យ $E$ ប្រដាប់ដោយប្រមាណវិធីក្នុង $*$ មានលក្ខណៈផ្តុំ ។ តាង $C=\{x\in E : \forall y\in E , x*y=y*x\}$

ក. បង្ហាញថា $C$ ជាផ្នែកស្ថាបនៃ $E$ ចំពោះប្រមាណវិធី $*$ ។

